


ROYAUME DU CAMBODGE
REGIE DU DEPOT LEGAL

B-8
D-37
N° 151

ភ.67

415

គិត-ឃារិន

▼

# ឧបករណ៍អនុពាក្យ

# LES ÉLÉMENTS DE DICTÉE

ARCHIVES NATIONALES
COTE
C/261

សំរាប់

## ការសិក្សាគ្រប់ថ្នាក់

ការផ្សាយរបស់

បណ្ណាគារ ឌុច-ឈឹង

លេខ ៨៨ រុក្ខវិថីឧកញ៉ាភ្លុង ផ្សារចាស់

ភ្នំពេញ

រក្សាសិទ្ធិ

# អាទិកថា

កាលនៅកំពុងសិក្សា ខ្ញុំតែងបានជួបប្រទះជាញឹកញយ
នូវកិច្ចការក្នុងអនុពាក្យខ្មែរ ដែលនាំឲ្យអ្នកសិក្សាខ្វះវង្វេង,
ប្រឡំ, ខុសស្ទើរតែលស់ខាន ៗ ការពើបពះនេះ បង្កើត
ទៅជាគំនុំមួយត្រៀមនៅក្នុងចិត្តរបស់ខ្ញុំជានិច្ច ដើម្បីនឹង
ដេញតាមកំចាត់នូវកិច្ចការទាំងនោះឲ្យបាន ៗ ដោយទេសៈ
កាលៈនេះ កម្មវិធីសិក្សាអក្សរសាស្ត្រជាតិបានរត់កាត់ទម្លាយ
កំពែងធំ ៗ ចូលទៅតាំងទីជាស្ថាពរនៅគ្រប់គ្រឹះស្ថានសិក្សា
ជាតិ ហើយកំពុងមានសកម្មភាពយ៉ាងរហ័សទៀតផង, ឱកាស
ឈប់សម្រាកប្រចាំឆ្នាំក្នុងឆ្នាំ ១៩៥៩នេះ នាំឲ្យខ្ញុំនឹកឃើញ
គំនុំរបស់ខ្ញុំចំពោះកិច្ចការនោះឡើងវិញ ។ កិច្ចការនេះ
បើរកវិធីកំចាត់មិនឃើញទេ មុខជារាំងនឹងស្តែងមាយាដាក់
អ្នកសិក្សារឹតតែខ្លាំងឡើង ៗ ទើបខ្ញុំរៀបរៀងវិធីកំចាត់ទាំង

នោះដាក់ជាមួយក្រុមឲ្យឈ្មោះថា «ឧបករណ៍អនុពាក្យ» នេះឡើង ដើម្បីជាគ្រឿងប្រដាប់សម្រាប់ជួយឧបត្ថម្ភដល់អ្នកសិក្សាក្នុងការតទប់ទឹងកិច្ចកលអនុពាក្យ ។ «ឧបករណ៍អនុ-ពាក្យ» ពុំមែនជាមេរៀនត្រូវចាំមាត់ទេ តែជាមេគំនិតមួយដែលជាមិត្រដ៏ប្រសើររបស់អ្នកសិក្សាអនុពាក្យខ្មែរ ។

ភ្នំពេញ, ថ្ងៃទី ៨ កក្កដា ឆ្នាំ ១៩៥៩

គិត-ហ៊ាង

# ការសរសេរអនុពាក្យ

ការសរសេរអនុពាក្យ ពុំមែនសំដៅទៅលើអក្សរល្អ មិនល្អ ឬសរសេរឲ្យគ្រាន់តែមើលកើត ដូចជាការសរសេរព្រាងនោះទេ គឺសំដៅលើលក្ខណៈច្បាស់ធ្ងិតធ្ងង់ ស្អាតបាតមានស្ថានភាពនៃដៃជើងតួអក្សរត្រឹមត្រូវ មិនវៀចឃ្វាតពីអក្ខរវិធី ពីព្រោះការសរសេរក្នុងពេលនេះមានគ្រូ ឬមេប្រយោគច្រើនរូបជាអ្នកចាំពិនិត្យ រកចាប់កំហុសរបស់យើង ៗ អ្នកចាប់ពិរុទ្ធ មិនមែនសម្លឹងមើលតែពាក្យខុសត្រូវប៉ុណ្ណោះទេ គេពិនិត្យមើលសព្វគ្រប់ទាំងតួព្យញ្ជនៈស្រៈជើងដើងនៃការសរសេររបស់យើង ៗ បើកាលណាយើងសរសេរមិនច្បាស់ ដាក់ដៃជើងមិនត្រូវតាមស្ថានភាពនៃលក្ខណៈអក្សរសាស្ត្រខ្មែរនោះ មុខជាយើងនឹងត្រូវអ្នកកែប្រែបិចប្រហោចយកកំហុសអស់ជាច្រើន ឲ្យទីងអក្ខរាវិរុទ្ធទៅទៀត ។

ដូច្នេះ មុននឹងចាប់សរសេរអនុវាក្យ គប្បីអ្នកសិក្សាហាត់សរសេរអក្សរខ្មែរ ឲ្យបានជាទម្លាប់ត្រឹមត្រូវពិតប្រាកដមែនទែនជាដរាប ។ ទម្លាប់ពិតប្រាកដរបស់យើង នឹងបានទទួលលទ្ធផលយ៉ាងគាប់ប្រសើរ ដែលអាចឲ្យយើងទុកចិត្តខ្លួនឯងកាន់តែវិសេសឡើង ។

១- ចូរប្រយ័ត្នតួព្យញ្ជនៈទាំងនេះ កុំសរសេរឲ្យច្រឡំគ្នា ភ-គ-ត-ក, ជ-ដ-ថ-ផ, ប-ម-ឋ, ឆ-ធ-, រ-វ, ល-ស, ហ-មា, ង-ឯ ។

២- ចូរសរសេរស្រៈនឹងជើងជើងទាំងនេះឲ្យច្បាស់ ។

ស្រៈ ុ កុំឲ្យច្រឡំជើង ្ឋ (ជើង ្ឋ កួចជួបគ្នា)

ស្រៈ ូ » ្វ (ជើង ្វ កួចជួបគ្នា)

ស្រៈ ឹ » ៉ (ស្រៈ ៉ មានចុងទក់)

ជើង ្យ " ឲ្យ (ជើង ្យ កួចក្បាលចេញក្រៅ)

ជើង ឲ្យ កុំឲ្យច្រឡំជើងយ្យ (ជើង ្រ ក្ដួចក្បាលចូលក្នុង)

ជើង ឋ „ ល្ល (ជើង ្ល ចុងឡើងលើ) ។

៣– ចូរប្រយ័ត្នតួផ្ញើជើងនឹងស្រៈ ា ។

ព្យញ្ជនៈណាដែមានផ្ញើជើង ហើយដាក់ស្រៈ ា ផង (ខ្លា) មិនត្រូវសរសេរផ្ញើជើងនៅខាងក្រោមស្រៈ (ខា្ល) ទេ ពីព្រោះមិនមានស្រៈណាមួយ អាចមានផ្ញើជើងទេ មានតែតួព្យញ្ជនៈទើបផ្ញើជើងបាន ។

១. ខ្លា, ឆ្មា, អាត្មា ។ល។ មិនត្រូវសរសេរជាខា្ល, ឆា្ម, អាតា្ម ដូច្នេះទេ ។

# ការអានអនុពាក្យ

យើងសង្កេតឃើញថា ក្នុងបណ្ដាសិស្ស ឬបេក្ខជនមួយថ្នាក់ ៗ តែងមានសមត្ថភាពពីរពួក ៗ ពួកទី ១ ជាអ្នកមានសតិល្អកែយល់ច្បាស់នូវអត្ថន័យនៃពាក្យ ហើយចេះចាំពាក្យ-ស័ព្ទជាច្រើនផង ៗ ពួកនេះបើទុកជាអ្នកអាន ៗ ប្រឡំពាក្យ ឬបន្ទុំយ៉ាងណាក៏នៅតែសរសេរត្រូវដែរ ៗ ពួកទី ២ ជាអ្នកមានសតិខ្សោយ មិនសូវចាំពាក្យអក្ខរាវិរុទ្ធ ហើយមិនយល់អត្ថន័យរបស់ពាក្យ ៗ ពួកនេះកាលណាអ្នកអានប្រឡំសូរស័ព្ទបន្តិចបន្តួច ក៏មិនអាចជៀសវាងកំហុសបានម្ដងឡើយ ហើយតែងត្អូញត្អែរថា អានមិនច្បាស់-មិនត្រូវ ៗ តើអ្នកអានត្រូវនិយមតាមពួកណា ?

ម្យ៉ាងទៀត ដោយប្រទេសនីមួយ ៗ តែងមានជនបទនៅដាច់សង្វែងពីគ្នា ឬដោយមាននិគមជនបទខ្លះតាំងនៅជាយដែនខុងកាត់មាត់ញក ពាក់ចង់ប្រហូកប្រហល់តែនឹង

ភាសាបរទេសនោះ, ក្នុងប្រទេសខ្មែរយើងសង្កេតឃើញថា អ្នកស្រុកភូមិភាគកណ្ដាលដូរតាមមាត់ទន្លេក្នុង ដូចជាស្រុកល្វាឯមជាដើម ច្រើននិយាយស្រៈអើប្រែទៅជាអែ (ដើម ជាដែម), ស្រៈអៀប្រែទៅជាអា (ទៀនជាតាន) ។ អ្នកស្រុកបាត់ដំបងភាគខ្លះ និយាយស្រៈអោ ប្រែទៅជាអូ (គោ ជា គូ) ។ អ្នកស្រុកសៀមរាប, ក្រចេះនិងលើកដែកភាគខ្លះ និយាយស្រៈអិ ប្រែទៅជាអួ (មាន់គក ជាមាន់គួក) ។ អ្នកស្រុកក្រចេះនឹងកំពង់ចាមភាគខ្លះ និយាយបំបាត់តួព្យញ្ជនៈពេលអស់ (ស្វាមួកំពោរគាប់ម៉ផ្លា ជា ខ្លាល្វ ពោរគាប់ម៉ក) ។ អ្នកស្រុកតាកែវភាគខ្លះ និយាយដើងដ ប្រែទៅជាដើងឌ (កណ្ដាល ជា កណ្ឌាល) ។ អ្នកស្រុកព្រៃវែងភាគខ្លះ និយាយស្រៈអាប្រែទៅជាអែ (តាញ ជាតែញ) ។ល។

ទោះបើមានការផ្សេងគ្នាដោយសមត្ថភាពនិងដោយការទម្លាប់និយាយដូច្នេះក៏ដោយ អ្នកអានត្រូវតែនិយមករណីយ-

កិច្ចរបស់ខ្លួនទៅតាមក្បួនអក្ខរវិធី ជាមូលដ្ឋាន ។ អ្នកអានត្រូវតែអានឲ្យច្បាស់ ៗ មានឃ្លាល្បះ មិនលឿនពេកមិនញាប់ពេក ហើយពាក្យនីមួយត្រូវអាននិយាយតាមតែអក្ខរវិធី និង វិធីអានប៉ុណ្ណោះ មិនត្រូវនិយាយតាមភាសានិយាយសាមញ្ញ ឬ តាមទម្លាប់អ្នកស្រុកនីមួយ ៗ នោះទេ ព្រោះការអានពាក្យសរសេរតាមសូត្រនេះ ពុំមែនជាការនិយាយពាក្យសាមញ្ញជួបសំដីគ្នាផ្សារនោះទេ គឺជាសូរស័ព្ទមានលក្ខណៈមានក្បួនច្បាប់ទៀងទាត់តាមក្បួនអក្ខរវិធីមួយ ដែលមានសិស្ស ឬ បេក្ខជនជាច្រើននាក់នៅចាំស្តាប់ប្រុងនឹងសរសេរតាមសំឡេង ។ ព្រោះហេតុនោះទើបការអានជាលក្ខណៈចាំបាច់សម្រាប់អ្នកសិក្សា ។

## ការអានខ្លះក្នុងភាសាខ្មែរ

តាមអក្ខរវិធី, ក្នុងភាសាខ្មែរយើងមានសំឡេងពីរ គឺអឃោសៈនិងឃោសៈ ។ ព្យញ្ជនៈដែលមានសំឡេងមិន

គឺកកង៏ ហៅថា អឃោសៈមាន ១១ តួគឺ កខ, ចឆ, ដឋ, តថ, បផ, ស ។ ព្យញ្ជនៈដែលមានសូរគឹកកង៏ហៅថា ឃោសៈ មាន ២១ តួគឺ គឃង៏, ជឈញ, ឌឍណ, ទធន, ពភម, យរលវ ហឡ ។

ព្យញ្ជនៈនៅចុងវគ្គ ៥ តួគឺ ង៏, ញ, ណ, ន, ម ហៅថា វគ្គន្តៈ ។ ព្យញ្ជនៈនៅសល់ពីវគ្គ ៦ តួគឺ យ, រ, ល, វ, ហឡ ហៅថា សេសវគ្គ ។

ចំពោះពាក្យពីព្យាង្គ, កាលណាមានព្យញ្ជនៈជាអ-ឃោសៈនៅជាប់ខាងដើម, ព្យញ្ជនៈជាវគ្គន្តៈនឹងសេសវគ្គ នេះ ត្រូវប្រែសំឡេងដើមរបស់ខ្លួនលំអោនទៅតាមព្យញ្ជនៈ អឃោសៈវិញ៖

| | |
|---|---|
| ក្រមា (ក្រម៉ា) | ខមាទោស (ខៈម៉ា.ទោស) |
| ចលនា (ចៈឡៈណា) | ឆាយា (ឆា.យ៉ា) |
| ដកប (ដ.ក៉ប) | ឋានៈ (ឋា.នៈ) |

តម្រា (ដំ.រ៉ា)   ថេរៈ (ថេ.រ៉ៈ)

ប្រមាញ់ (ប្រម៉ាញ់)   ផលា (ផៈ-ឡា)

សង្ការ (សង់ ក៉ារ)   ស្រព (ស្រ-ព៉) ។ល។

លើកលែងតែពាក្យខាងក្រោមនេះ ដែលគណៈកម្មការវប្បធម៌សន្មតឲ្យអានតាមសម្រួល ៖

ស្ថានីយ ឲ្យអានថា (ស្ថា-នីយ) មិនឲ្យអានថា ស្ថា.ណីយ-ទេ

ខែមីនា ,, (ខែ-មីណា) ,, មីនា-ទេ

សម្ដេចព្រះមហាក្សត្រិយានី ឲ្យអានថា (ត្រិយ៉ា.នី) មិនឲ្យអានថា យ៉ា.ណីទេ ។

មានព្យញ្ជនៈ ១៧ តួគឺ កខគឃ, ចឆជឈ, ដឋឌឍ, តថទធ, ស បើទុកជាមានព្យញ្ជនៈដទៃនៅជាប់ខាងដើមក៏មិនអាចដួលសំឡេងស្របទៅតាមបានដែរ ៖

ក. និកាយ (មិនអាចជា និគាយទេ) ខ. សង្ខារ (មិនអាចជាសង្ឃារទេ)

គ. សង្គម ( ,, ស័ង-ក័មទេ) ឃ. សង្ឃឹម ( ,, ស័ង-ខឹមទេ)

ច. វិហារ (មិនអាចវិហារទេ) ឆ. គូធាយ (មិនអាចគូ.ឈាយទេ)

ជ. បញ្ជី ( „ បញ្ជីទេ ) ឈ. បញ្ជរ ( „ បញ្ចរទេ)

ដ. ពិដោរ ( „ ពិឌោរទេ) ឋ. ពាឋា ( „ ពា-ធាទេ )

ឌ. បណ្ឌិត ( „ បណ្ដិតទេ) ឍ. អឌ្ឍៈ ( „ អដ្ឋៈទេ )

ត. ជតា ( „ ជះតាទេ ) ថ. ពូថៅ ( „ ពូធៅទេ)

បន្ទាត់ ( „ បន្ដាត់ទេ ) ធ. បន្ធរ ( „ បន្ទរទេ)

ស. ពិសារ (មិនអាចជាពិសារទេ)

---

## ពាក្យដែលមានយុគលពិន្ទុ (:)

ពាក្យជាឯកព្យាង្គដែលមានស្រៈអះខាងចុង, កាលណាមិនមានសញ្ញាយុគលពិន្ទុទេ មិនត្រូវអានឲ្យចេញសូរជាអះទេ ៖

កម្ម, កាយ, រូប, សម្ផស្ស, ឧទ្ទិស, ចិត្ត ។ល។ មិនត្រូវអានថា កម្មៈ, កាយៈ, ។ល។ ទេ ។

- បើមានយុគលពិន្ទុ ទើបត្រូវអានឲ្យមានសូរ អះ ៖ កម្មៈ គណៈ ទស្សនៈ, វណ្ណៈ, សុខៈ, ពលៈ ។ល។

បើពាក្យជាពីរព្យាង្គ ឬដែលតភ្ជាប់ជាបទពីរ (សមាស) ត្រូវអានភ្ជាប់គ្នា ឲ្យមានសូរស័ព្ទយុគលពិន្ទុជា អះ ជាដរាប៖

កាយកម្ម (កាយ+កម្ម) ត្រូវអានថា កាយៈកម្ម,

កម្មករ (កម្ម+ករ) ” កម្មៈ-ករ,

ធម្មតា ” ធម្មៈ-តា ។ល។

មិនត្រូវអានកំបុតសំឡេងថា កាយ-កម្ម, កម្ម-ករ, ធម្ម-តា ដូច្នេះទេ ។

## ពាក្យដែលមានស្រះរស្សៈខាងចុង

ពាក្យដែលមានស្រះរស្សៈ (អ.អិ អុ) នៅខាងចុង(ខេត្ត, ជាតិ, ហេតុ) គេច្រើនតែបំបាត់សំឡេងស្រះរស្សៈចោល មិនអានឲ្យពេញជង់ទេ ៖

អ = ខេត្ត, ខណ្ឌ, ឯកច្ឆ័ន្ទ ។ល។

អិ = ជាតិ, បញ្ញត្តិ, វិប័ត្តិ, អនុម័តិ, ធម្មជាតិ ។ល។

អុ = ហេតុ, ធាតុ ។ល។

លើកលែងតែពាក្យខ្លះ ដែលនិយមអានជាទម្លាប់ជាប់តាមពីកំណើតបាលីតាំងស្រេចមកហើយ, ពាក្យខ្លះទាំងនេះត្រូវអានទុកសម្រេចឲ្យគង់វង់នៅដដែល ៖

ញត្តិ (ញ៉ាត់-តិ), ប្រជាមតិ, បដិសន្ធិ, សន្និធិ, សិទ្ធិ, ឧត្តមគតិ, កម្មវត្ថុ, ហិរញ្ញវត្ថុ ។ល។

## ពាក្យដែលមានស្រៈរស្សៈនៅកណ្ដាល

ពាក្យដែលមានស្រៈរស្សៈនៅកណ្ដាល ត្រូវតែអានឲ្យមានសូរស័ព្ទរស្សៈ (សូរខ្លី) ជាដរាប ៖

កម្មករ (កម្-ករ), ធម្មតា, កិត្តិនាម, នីតិក្រម, បាតុភូត ចតុភូមិ ។ល។

## ពាក្យដែលមានតួ «រ» ប្រកបជាមួយ

បើតួ «រ» នៅខាងចុងបំផុត «រ» ជាព្យញ្ជនៈឥត

សំឡេង មិនត្រូវអានឲ្យឮសូរជាអ៊ូឡើយ ៖

ត្រេកអរ, សាគរ, ហានន្តរ, កម្មករ, បវរ, គោចរ, ទេពអប្សរ, ព្រះវេស្សន្តរ ។ល។

បើតួ «រ» ឋិតនៅត្រង់កណ្ដាលពាក្យ, «រ» មានសូរគង់វង់ជា "រ" ដដែល តែសូរខ្លី-រហ័សភ្ជាប់ទៅនឹងបទខាងចុង៖

ពាក្យដែលធ្លាប់ប្រើ

បរទេស (ប-រ-ទេស), បរប័ក្ស (ប-រ-ប័ក្ស),

បរលោក (ប-រ-លោក), នរនាថ (ន-រ-នាថ) ។ល។

វៀរលែងតែពាក្យពីរម៉ាត់ខាងចុងនេះ, "រ" មានសូរជា «រ» វិញ ៖

អន្តរជាតិ (អន្ត:-រ:ជាតិ)

វិរជន (វិ:-រ:-ជន់)

ពាក្យដែលមានស្រៈ ា ប្រកប «រ» (ារ)

ពាក្យទាំងនេះ "រ" មានសំឡេងជា «ល» វិញ ៖

កណ្ដុរ (កណ្ដុល), ខ្ទុរ (ខ្ទុល), ខុរ (ខុល), ខ្ពុរ (ខ្ពុល), ខ្សុរ (ខ្សុល), ធុរ (ធុល), បង្អុរ (បង្អុល), ផុសផុរ (ផុសផុល), ផ្កុរ (ផ្កុល), ផ្លុរ (ផ្លុល), ពពុរ (ពពុល), អសុរ (អៈសុល) ។

---

## ស្រៈ ិ អានជា ី

ពិដក (បី-ដក់), បិតា (បី-ដា),

បិសាច (បី-សាច), វិថិ (វិ.ថី)

អវិចិ (អៈ-វិ-ចី) ។ល។

ចំណាំ.- វិថិ និង អវិចិ នេះ ជាស័ព្ទដើមនៃបាលីសុទ្ធសាធ តែខ្មែរយើងសរសេរក្លាយតាមអានថា វិថី, អវិចី ដូច្នេះទៅហើយ ។

## ស្រៈ ី អានជា ិ

ហីនហោច (ហិន-ហោច), អតីត (អៈ-ដិតឬ-ឌិត),

សន្និសីទ (-សិទ), ក្សីណក្ស័យ (ក្សិណក្ស័យ) ។ល។

កំណត់.– គេអាចសរសេរជា ហិនហោច, សន្និសិទ, ក្សិណក្ស័យតាមតានក៏បាន, តែចំពោះអតីត គេមិនដែលសរសេរជាអតិតទេ ។

ស្រៈ ិ នឹង ី ប្រកប "រ" អានថា "អឿ"

សិរ្សមាន់ (សេរ-មាន់), ទឹកក្សីរ (ទឹក-ក្សេរ), បីរកាល (បេរ-កាល) ។ល។

---

េ-យ្យ មានសូរជា-អ័យ

អធិបតេយ្យ (-ត័យ), ឧបមេយ្យ (-ម័យ), គណនេយ្យ (-ន័យ), ឧទេយ្យ (-ទ័យ), នាមាភិធេយ្យ (-ធ័យ), គេយ្យាកាត (ក័យ-), បត្តេយ្យសាលា (-ត័យ-) ។ល។

-ែ- អានជា -ៃ-

ពាក្យក្លាយពីបាលី ឬ សំស្រ្កឹតដែលជាឣឃោសៈ ខ្មែរ

យើងច្រើនអានបំប្លែង េ-ជា ែ-៖

ចេតនា (ចែ-), ខែចេត្រ (-ចែត),

ខេត្ត (ខែត) ខេមរា (ខែម-រ៉ា) ។ល។

លើកលែងតែ ហេតុ, ហេមរដូវ ត្រូវអានថា ហែតុ, ហែមៈ រដូវ ។

– ដែលជាឃោសៈ ច្រើនអានថា -េ-ជាដែល៖

ប្រភេទ, វេជ្ជបណ្ឌិត, ជលនេត្រ, មេឃ, លេស, កិលេស, និវេសន៍, ប្រទេស ។ល។

វៀរលែងតែ ពេទ្យ ត្រូវអានថា ពេទ្យ ។

## ឃ. គិតសំឡេង

អក្សរ «ហ» កាលបើប្រកបជាមួយនឹងជើង ន្ហ, ម្ហ, ល្ហ, វ្ហ ច្រើនតែបាត់សូររបស់ខ្លួន មានតែសំឡេងជើងព្យញ្ជនៈប៉ុណ្ណោះ៖

ហ្ន (អ.ន.)

ស៊ីហ្ន! (-ន អានថា ... ន ស្បូរខ្ពស់ជាងនប្រក្រតី), អ្នកណាហ្ន!, អើហ្ន៎!, អើហ្នឹងហើយ! (-នឹង), ហ្នប៉្ញាក់ (ស.) (ណា.ប៉ាក់)= សំពត់ដែលគេប៉ាក់ពាសមុខខ្នូគង, ខ្នុរហ្ន័ង, ហ្នាំង ឬ ណាំង (ស.) ។

ហ្ម (អ.ម៉)

ពេទ្យហ្ម (ស.) (-ម៉), ហ្មដំរី, ហ្មជាវ, ហ្មទួត (ស.) អ្នកប្រសប់ចាប់សរសៃ, ហ្មត្វាម (ស.) អ្នកស្មាគ្គី, ហ្មង (ម៉ង) (ស.) សៅហ្មងចិត្ត, ហ្មត់ (ស.) ហ្មត់ចត់ ឬ ម៉ត់ចត់ (ស.), ហ្មត់-ហ្មង (ស.), អង្គុយហ្មប (ស.), ហ្មបហ្មយ, បុតហ្មត, នាហ្មឺន ឬ ម៉ឺន, មួយហ្មឺន ឬ ម៉ឺន, ហ្មូត ឬ ម៉ូត ។

ហ្ល (អ.ឡ)

ហ្លាក់ ឬ ឡាក់ហាន (ស.), ហ្លាក់ហ្លាំង ឬ ឡាក់ឡាំង (ស.), តាំងហ្លាយ ឬ តាំងឡាយ (ស.), ហ្លួង (ស.) ។

## ហ្វ (វ៉)

ហ្វង់ (វ៉ង់), ហ្វឹកហាត់, ហ្វឹកហ្វឺន, ហ្វូង, គាល់ហ្វៅ, ចៅហ្វាយ, ចានហ្វាង, ផហ្វា ។

## ហ្ស (បារាំង J ឬ G)

ហ្សេណេរ៉ាល់, អ័ដហ្ស៊ុយដង់, រថយន្តហ្ស៊ីប ។ល។

## ស្ហ (បារាំង Ch)

ស្ហឹវ៉ាលីយេរ, ស្ហូហ្វ័រ ។ល។

---

## អើយ

១– បើព្យញ្ជនៈនៅខាងដើមជាប់នឹង «អើយ» មានសូរស្រួលស្តាប់ ដូចជា -ក, -ង, -ញ, -ន, -ម, -យ, -ស ជាដើម គេច្រើនអានភ្ជាប់ (liaison) សំឡេងព្យញ្ជនៈនេះទៅនឹង "អើយ" ៖

អ្នកអើយ! អានភ្ជាប់ថា អ្នក-កើយ!

នាងអើយ!　　អានភ្ជាប់ថា　នាង-ង៉ើយ!

សំឡាញ់អើយ!　　„　　សំឡាញ់-ញ៉ើយ!

ប្អូនអើយ!　　„　　ប្អូន-ណើយ!

កម្មអើយ!　　„　　កម្ម-ម៉ើយ!

យាយអើយ!　　„　　យាយ-យ៉ើយ!

ម្ចាស់អើយ!　　„　　ម្ចាស់-ស៊ើយ!

ព្រលឹងមាសអើយ!　„　　ព្រលឹង-មាស-ស៊ើយ!

២-បើពាក្យដែលនៅខាងដើម «អើយ» មានព្យញ្ជនៈតម្រួត (ព្រះអង្គ-អើយ) ឬពាក្យដែលឥតអក្សរប្រកប មានតែស្រៈទទេ (តា-អើយ), អើយ នឹងអានភ្ជាប់សំឡេងដូចបែបទី១ ពុំបានឡើយ ព្រោះបើភ្ជាប់ទៅនាំឲ្យមិនស្រួលស្តាប់ ឬនឹងអានថា «អើយ» ទទេដូច្នេះ ក៏នៅតែមិនស្រួលស្តាប់, ត្រូវអានថា "អ្ហើយ" ជាសំឡេងស្រាល!

ព្រះអង្គអើយ!　　ត្រូវអានថា　　ព្រះអង្គ-អ្ហើយ!

| | | |
|---|---|---|
| ភិក្ខុអើយ! | ត្រូវអានថា | ភិក្ខុ-អ្ហើយ! |
| ព្រះពុទ្ធអើយ! | „ | ព្រះពុទ្ធ-អ្ហើយ! |
| តាអើយ! | „ | តា.អ្ហើយ! |
| មាអើយ! | „ | មា.អ្ហើយ! |
| ពូអើយ! | „ | ពូ.អ្ហើយ! |
| ទេវតាអើយ! | „ | ទេវតា.អ្ហើយ! |

## ហោង៍ (អ្ហង៍)

ជាពាក្យបូរាណលោកច្រើនប្រើនៅពេលបញ្ចប់រឿង ដើម្បីឲ្យអ្នកស្តាប់ឬអ្នកអានយល់ថា រឿងនោះចប់តែប៉ុណ្ណោះ ឥតមានតទៅទៀតទេ៖

– ចប់តែប៉ុណ្ណោះឯងហោង៍ (អ្ហង៍) ។

– សូមឲ្យបានសម្រេចព្រះនិព្វានហោង៍ (អ្ហង៍) ។

# ពាក្យពិបាកក្នុងអនុពាក្យ

យើងបានចែកពាក្យពិបាកជា ៤ ពួក គឺពាក្យពិបាក ដែលទាក់ទងដោយវណ្ណយុត្តិខ្លះ, ដោយស្រៈពេញតួ, ដោយស្រៈនិស្ស័យ, ដោយតួព្យញ្ជនៈ និងដោយសព្ទវេយ្យាករណ៍ ។

ក្នុងមួយពួកៗ យើងបានដកស្រង់ពាក្យជាឧទាហរណ៍យ៉ាងច្រើនស្ទើរតែគ្រប់គ្រាន់ សម្រាប់ជាគ្រឿងចំណាំដល់អ្នកសិក្សា ។ ចំពោះពាក្យពិបាកដែលទាក់ទងដោយស្រៈនិស្ស័យ (ក និង គ ប្រកបនឹងស្រៈ ួ - ឿ - ៀ) យើងបានដកយកតែខាងព្យញ្ជនៈណា ដែលមានចំនួនពាក្យតិច ដូចជា ក និង គ, យើងលើកយកតែខាងព្យញ្ជនៈ គ ជាឧទាហរណ៍ មាន ៧ ពាក្យ (គួប, គួរ, គ្រួបៗ, គ្រួសារ, គ្រឿង, គ្រឿន, គ្រៀស), ហើយខាងចុងយើងចុះ

សេចក្ដីសន្មតិថា «ក្រៅពីនេះ សុទ្ធតែជាអក្សរ ក ទាំងអស់» តបអ្នកសិក្សា សង្កេតចំណាំតែខាងអក្សរ គ ៧ ពាក្យនេះប៉ុណ្ណោះ ក្រៅពីនេះ កាលបើមានពាក្យដែលប្រកបនឹងស្រៈ ួ - ឿ - ៀ មានសូរជា ក ឬ គ មិនដាច់ស្រេចនេះ ត្រូវតែអ្នកសិក្សាសរសេរខាងអក្សរ ក ទាំងអស់ចុះមិនខុសទេ ។ ឯពាក្យពិបាកដែលទាក់ទងដោយព្យញ្ជនៈ (ក្មេង ឬខ្មេង) ក៏មានលក្ខណៈដូចគ្នានឹងន័យនេះដែរ ។

---

## ពាក្យពិបាក
## ដែលទាក់ទងដោយវណ្ណយុត្តិខ្លះ

### របស់សញ្ញាបន្តក់ ( ់ )

សញ្ញា ( ់ ) នេះ សម្រាប់ដាក់នៅលើព្យញ្ជនៈដែលជាស្រៈ “អ” (កប់) និងស្រៈ ា (កាប់) នៅខាងដើម ដើម្បីបំប្លែងសំឡេងឲ្យខ្លីកំបុត៖

ឧ. កត់, អំណត់, ចប់, កាល់, ចាប់, អាប់ ។ល។

ចំណាំ.- ១- ចំពោះស្រៈ ា ប្រកប «ង» ខាងចុង មិនត្រូវដាក់បន្តក់ ( ់ ) នេះទេ ត្រូវប្រើនិគ្គហិត ( ំ ) នេះនៅពីលើស្រៈ ា ជំនួសវិញ៖

ឧ. កាំង, ខាំង, គាំង, ឃាំង, ចាំង, មាំង ។ល។

មិនដាក់បន្តក់នៅលើ «ង» ជា «កាង់, ខាង់, គាង់, ឃាង់, ចាង់, មាង់» ដូច្នេះទេ ។

២- ចំពោះស្រៈ ា ប្រកប «ច» ខាងចុងអាចដាក់បន្តក់បានទាំងអស់ ។ វៀរលែងតែពាក្យទាំងប៉ុន្មានខាងក្រោមនេះ ដែលមានសំឡេងដូចស្រៈ ា ប្រកប «ច» ដែរ តែបែរជាត្រូវដាក់ស្រៈ េ-ច ជំនួសវិញ៖

សេចក្ដី, សេចក្ដាំ, ស្រេច, សម្រេច, សម្ដេច, ស្ដេច ប្ដេជ្ញា, ផ្ដេច ។ (អានថា-សាច់ក្ដី, ស្រាច់, ស្ដាច់, ផ្ដាច់)

៣– សេស្រសញ្ញា ឬ បន្តក់នេះ ប្រើបានចំពោះតែពាក្យខ្មែរសុទ្ធប៉ុណ្ណោះ ឯពាក្យក្លាយមកពីបាលីឬសំស្រ្កឹតដែលមានឫស្បូរខ្ចី-កំបុតដូចជាសេស្រសញ្ញាដែរនោះ មិនចាំបាច់ប្រើបន្តក់នេះទេ ។

## ពាក្យឥតបន្តក់ដែលធ្លាប់ប្រើ

| | |
|---|---|
| កុសល (កុសល់) | កុហក (កុហក់) |
| អាគម (អាគម់) | អនាគត (អៈណា-គត់) |
| ជន (ជន់) | ផល (ផល់) |
| កព (កព់) | មណ្ឌល (មន់-ឌល់) |
| ធន (ធន់) | តាបស (តា-បស់) |
| នាយក (នាយក់) | ជាតក (ជាដក់) |
| អាជីវក (អាជីវក់) | នរក (ន-រក់) |
| លាមក (លាមក់) | ភ្ញក្យ (ភ្ញក់) |

សុគត (សុគត់) ទុគ៌ត (ទុគ៌ត់)

ទុព៌ល (ទុព៌ល់) ទុយ៌ស (ទុយ៌ស់)

## ត្រីស័ព្ទ ( ៊ )

វណ្ណយុត្តិនេះ សម្រាប់ដាក់តែនៅលើព្យញ្ជនៈ ៤ តួគឺ ប ស ហ អ ដើម្បីបំប្លែងសំឡេងតូច (អ) ទៅជាសំឡេងធំ (អ៊) ប៊ ស៊ ហ៊ អ៊ ៖

១. ប៊ុន, ស៊ង, ហ៊ាន, អ៊ុន ។

- លោកប៊ុនទិញកៅស៊ូពីក្រុមហ៊ុនស៊ុន ។

ចំណាំ. ១- ចំពោះព្យញ្ជនៈ ប៊ ខ្មែរយើងមានប្រើតែ សាប៊ូ មួយប៉ុណ្ណោះ ក្រៅពីនេះគេច្រើនប្រើក្នុងពាក្យឈ្មោះរបស់មនុស្ស ដូចជាឈ្មោះ ប៊ិន, ប៊ុត, ប៊ុន ជាដើម។

២.- ស៊ ហ៊ កាលណាមានស្រៈ ( ិ ី ឹ ឺ )

នៅខាងលើត្រូវផ្លាស់ ( ៊ ) នេះ ទៅជាក្បៀសខាងក្រោមវិញ ( ុ )៖

១. សុី, ម៉ាសុីន, កូសាំងសុីន, លេងហុី, ហុីហាៗលៗ

៣- ស៊ិ ហ៊ិ កាលណាមានសំឡេង ( ុំ ) នៅជាមួយ មិនត្រូវដាក់ ៊ នៅពីលើ ( ុំ ), ត្រូវផ្លាស់ ៊ ជា «ម» វិញ៖

១. ស៊ុមគ្រលុំ, ស៊ុមទ្រុម, ស៊ុមមាន់, ហ៊ុមព័ទ្ធ, ផាហ៊ុម, ល្ហានហ៊ុមពេង, ហ៊ុមហ ៗលៗ

មិនត្រូវសរសេរ ស៊ុំ, ហ៊ុំ ដូច្នេះទេ ។

៤- ស៊ិ បើមានសម្លេង ( ាំ ) នៅជាមួយត្រូវផ្លាស់ ( ៊ ) នេះទៅជាក្បៀសក្រោមវិញ ( ុ )៖

១- សុាំបិត្ត, សុាំគំនិត, សុាំកម្លាំង, សុាំស៊ិន ៗលៗ

មិនត្រូវសរសេរ ស៊ាំ ដូច្នេះទេ ។

៥- អ៊ិ បើមានស្រៈ ( ិ ី ឹ ឺ ) នៅពីលើមិនត្រូវផ្លាស់

(៎) ហៅជាកៀសក្រោម (ˏ) ដូចជា សិ៎ ហ៎ ទេ ត្រូវទុកឲ្យនៅដដែល៖

១– អ៎ះអុ៎ះ, អកអាក់, អ៎ា, អកអាក, អ៎ប៉ន, អ៎ប៉ុន, អ៎ប៉ុះ, អ៎ប៉េះ, អ៎គែ, អ៎ថា: អកជក ឬអកអជក, អ៎ន, អ៎ម ឬអម៉ោះ, អ៎ះ, អ៎ះអ៎ះ, អុ៎ះអ៎ះ, អ៎, អ៎ត, ក្រុបអ៎ត, អ៎ះ! ។

## មូសិកទន្ត ឬធ្មេញកណ្ដុរ (៉)

សញ្ញា (៉) នេះ សម្រាប់ដាក់នៅលើព្យញ្ជនៈ ៩ តួ គឺ ង ញ ន ប ម យ រ ល វ ដើម្បីបំប្លែងសំឡេងឲ្យទៅជា ង៉ ញ៉ ន៉ ប៉ ម៉ យ៉ រ៉ ល៉ វ៉ ៖

១. បុណ្យង៉ាន, ញ៉ាម, ម៉ោង, រៀនភាវ, ព៉ន់ស៊ុយ ។ល។

ចំណាំ.–១– បើកាលណាមានស្រៈ( ិ ី ឹ ឺ ើ ំ)

ទៅពីលើ ត្រូវផ្លាស់ (") ទៅជាក្បៀសក្រោម (,) វិញ៖

១. ប៉ុ, មុឺនម៉ាត់, ញុាំ ។ល។

២- បើកាលណា មានពាក្យពីរព្យាង្គ ហើយព្យាង្គខាងមុខមានសំឡេងស្របទៅតាមព្យាង្គខាងដើម ក៏មិនត្រូវប្រើ (") ដែរ៖

១ កន្ធល់, បញ្ញា, ប្រមាថ, ស្រវឹង, ចម្លែក ។ល។ មិនត្រូវសរសេរ: កន្ធ៉ល់, បញ្ញ៉ា, ប្រម៉ាថ, ស្រវុឹង, ចម្ល៉ែក ដូច្នេះទេ ។

## សំយោគសញ្ញា (៍)

សញ្ញា (័) នេះ សម្រាប់ដាក់នៅលើព្យញ្ជនៈ ជា ស្រៈ (អ) ទី២ (កប់ពីខាងស្ដាំដៃមកឆ្វេង) ដើម្បីបំប្លែងសំឡេងដើមឲ្យទៅជាស្រៈ ែ - ឬ - ា ប្រកបនឹងព្យញ្ជនៈ

ខាងចុង ។ គេប្រើចំពោះពាក្យដែលក្លាយពីបាលីឬសំស្ក្រឹតមក៖

១. ក្ស័យ, ជលស័យ, ពិសម័យ, ជ័យ, វិន័យ, ន័យ, ជលន័យន៍, ទិនក្ស័យ, ទ័លក្រ, ភ័យ, វិស័យ, និស្ស័យ, ទិព្វ័ន, វិនិច្ឆ័យ, ទៅវិនិច្ឆ័យ, នភាល័យ, អាល័យ, សម័យ, អនាម័យ, និរភ័យ, នព្វ័តន៍, ឧត្តលវ័យ, ពនាល័យ, រហ័ស, អាស្រ័យ, វេស្ម័ន, វេស្យ-វ័ណ្ណ, បរិស័ទ, បរាសម្ព័ទ, ប្រល័យ, ប្រាស្រ័យ, ពិជ័យសង្គ្រាម, អាត្ម័ន, វិទ្យាល័យ, បណ្ណាល័យ, ត្រ័យត្រឹង្ស, ព្រះទ័យ, មនោម័យ, ក្សីណក្ស័យ, ប្រល័យ-កល្ប, អយស្ម័យយាន, ពិនិស្ច័យ, អាយ័ត, បច្ច័យ, នំប័ក្កប័ន, ប្រប័ណ្ឌ, ប្រយ័ត្ន, ភ័ព្វ, ប្រវ័ញ្ច, និលរ័ត្ន, នារីរ័ត្ន, ភ័ក្ត្រ, ពិភ័ក្តិ, ល័ក្ខខណ្ឌ, ម្រ័ក្សណ៍, លាយល័ក្ត-អក្សរ, ស័ថ្ត, ស័ព្ទ, ស័ក្តិសិទ្ធិ, ស្រអ័ព្ទ, ស្ម័គ្រ ។

គ័ភ៌, ទក្ខិណាព័ត៌, ព័ណ៌, ព័ទ្ធ, ពន្ធព័ទ្ធ, ពិព័ទ្ធ, យ័ន្តឬយ័ន្ត្រ, ល័ទ្ធ, ពិព័ណ៌ ៗ

ចំណាំ.– ១–សំយោគសញ្ញា ( ័ ) នេះ គេប្រើក្នុងពាក្យខ្មែរសុទ្ធក៏មានខ្លះ ៖

១. ខ្ញ័រ, ជ័រ, ញ័រ, ទទ័រ, ឡទ័រ, ទំព័រ, ទំប៉ុង, ស្បរប៉ុង, ក្ឈ័រ, ផ្លែសណ្ឋ័រ, ដើមសំព័រ, ស្ពាន់ជ័រ ៗ

២– ក្នុងពាក្យបារាំងដែលសរសេរជាអក្សរខ្មែរក៏មានខ្លះ ៖

១. ដុកទ័រ, ឌីរ៉ិកទ័រ, អ័ងស្ប៉ិកទ័រ, កុងត្រូល័រ, ស្បូហ្ស័រ ៗ

វិធាន (៣)

សញ្ញា ( ៌ )នេះ សម្រាប់ប្រើចំពោះតែពាក្យ ដែល

ក្លាយមកពីសំស្ក្រឹតប៉ុណ្ណោះ ដើម្បីបំភ្លៃងសំឡេងឲ្យព្ធស្បូរ ញ័រ៖

## ពាក្យដែលធ្លាប់ប្រើ

១. គភ៌, ទុគ៌ត, ទុព៌ល, ទុគ៌ម, ទុយ៌ស, ធម៌, បព៌ត, ពណ៌, អាថ៌, ពត៌មាន (ព័រ-ដមាន), ទ៌ទ៌ុក្ខ, ទ៌ភ៌យ ។ (ពាក្យទាំងនេះក្លាយមកពីបាលីថា គព្ភ, ទុគ្គត, ទុព្វល, ទុយស ធម្ម, បព្វត, វណ្ណ, អត្ថ, វឌ្ឍមាន, ទ៌ទុក្ខ, ទ៌ព្ភយ ។

ចំណាំ.– ១ កាលណាមានស្រៈ ៌ នៅជាមួយ, ដើម្បីជៀសវាងកុំឲ្យមានការទើសទាស់ច្រើន, ត្រូវដាក់អក្សរ «រ» ពេញតួពីលើព្យញ្ជនៈខាងចុងតែម្ដង៖

១. ពមរ្គ៍, ទុរ្ក្យ, តិរ្យ, អន្យតិរ្យ ។

២.– ពាក្យខាងក្រោមនេះ ក៏ខ្មែរយើងនិយមសរសេរ អក្សរ «រ» ពេញតួដែរ៖

៤. អារ្យធម៌, អស្ចារ្យ, អាចារ្យ, អនាចារ្យ ។

៣ – ពាក្យខាងក្រោមនេះ អាចប្រើបានពីរបែប ៖

ទុគ៌ម, ទុព៌ល, ទុយ៌ស, ទុគ៌ត, បព៌ត, និទ៌ុក្ខ, និភ៌យ; បើសរសេរ "រ" ពេញតួ: "ទុរគម, ទុរពល, ទុរគត, បរពត, និរទុក្ខ, និរភ័យ" ដូច្នេះក៏បាន ។

## ទណ្ឌឃាត (៍)

សញ្ញា (៍) នេះ សម្រាប់ដាក់នៅលើព្យញ្ជនៈខាងចុង នៃពាក្យ ដែលក្លាយពីបាលីនិងសំស្រ្កឹត ដើម្បីសម្គាល់ សំឡេងតួអក្សរនោះកុំឲ្យឮសូរ ៖

ពាក្យដែលធ្លាប់ប្រើ

ប្រយោជន៍, អាពាហ៍ពិពាហ៍, ព្រះមហាក្សត្រិយ៍, ព្រះ

រាជនិវេសន៍, វេហាស៍, យោជន៍, រុងរោចន៍, អគិរូហ៍, វេយ្យា-ករណ៍, សហករណ៍, ព្រឹត្តិការណ៍, អ្នកចោទក៍, អ្នកពេជ្ឈ-ឃាតក៍, អ្នកឧបត្ថម្ភក៍, ការប្រវ័ញ្ចន៍, ការពិសោធន៍, ការអនុ-វត្តន៍, ការបរិវត្តន៍, ការបដិវត្តន៍, ស្រមណ៍, ព្យាករណ៍, ដំណើរនិវត្តន៍, ភេទ៍, ថ្ងៃសៅរ៍, ខែស្រាពណ៍, សតវត្សរ៍, ពិព័រណ៍, ភ្នំព្រះសុមេរុ៍ (សុ-ម៉ែ), ក្រាបប្រណិប័តន៍, និវេសន៍, ហេតុការណ៍ ។

## លេខអស្ដា (៨)

សញ្ញា ( ៏ ) នេះ សម្រាប់ដាក់នៅលើព្យញ្ជនៈបួនតួគឺ ក, ដ, ហ, ន ដែលជាពាក្យខ្មែរសុទ្ធ ដើម្បីបំប្លែងសំឡេងឲ្យឮសូរខ្លី ៖

## ពាក្យដែលធ្លាប់ប្រើ

ក៏ = ក៏ដោយ, លោកក៏ដោយ, ខ្ញុំក៏ដែរ, ក៏បាន ។

ដ៏ = ដ៏ប្រសើរ, ដ៏ឧត្ដម, ដ៏ខ្ពង់ខ្ពស់, ដ៏ហើយ (បាន ន័យថាសង់, ធ្វើ) ។ ឮដ៏: (បានន័យថា ឯ)

ហ៏ = ហ៏យកក់ទៅ ។

ន៏ = នុ៎ះន៏ ។

ចំណាំ:— ១ ក ជាកិរិយាស័ព្ទ នឹងនាមស័ព្ទមិនត្រូវ ដាក់ ( ៏ ) ទេ ក សាង, កមនុស្ស ។

២ – ដទៃ, ដពប, ដដែល, មិនត្រូវដាក់ ( ៏ ) ទេ ។

## យុគលពិន្ទុ ( : )

សញ្ញា ( : ) នេះ សម្រាប់ចុចនៅមុខពាក្យក្លាយមកពី បាលីនឹងសំស្រ្កឹត ដើម្បីសំគាល់ឲ្យដឹងថា ព្យញ្ជនៈដែលមាន

ចុច (:) នេះត្រូវអានឲ្យមានសំឡេងជា «អាក់» (អៈ)៖

ពាក្យដែលធ្លាប់ប្រើ

គណៈ, ទស្សនៈ, ធុរៈ, វណ្ណៈ, សុខៈ, ពលៈ, ភារៈ, ជាវៈ, ឃោសៈ, អាដីវៈ, ឋការៈ, តាសៈ, បដិសណ្ឋារៈ, សម្ភារៈ, វិរិយៈ, ឋស្សាវៈ, វស្សៈ, ទីឃៈ, អក្ខរៈ, ព្យញ្ជនៈ, ភាវៈ, ភេសជ្ជៈ, មរណៈ, លក្ខណៈ, លាភៈ, លោភៈ, ទោសៈ, មោហៈ, ភាជនៈ, សក្ការៈ, សមណៈ, សម្បជញ្ញៈ, ខេមរៈ, ស្រៈ, សារៈ, សភាវៈ, សេនាសនៈ, អមតៈ, អាយតនៈ, ឧបការៈ, មោឃៈ ។

បំណាំ.— ១ ពាក្យណាជាសមាសនាម (ដែលមានបទពីរភ្ជាប់គ្នា: ខេមរ + ភាសា = ខេមរភាសា) ត្រូវអានឲ្យមានសំឡេងដូចជាមាន (:) ដែរ តែមិនត្រូវ ចុច (:) នេះជាដាច់ខាត៖

យុវជន, យុវនារី, ឧបការគុណ, វិស្សមកាល,

មរណភាព, ខេមរជាតិ, បដិសណ្ឋារកិច្ច, ព្រះរាជបុត្រ, សក្ការបូជា, អាជីវកម្ម ៗ

( មិនត្រូវចុច : យុវៈជន ដូច្នេះទេ )

២–ចំពោះពាក្យ «គណៈ» ទោះបីភ្ជាប់ដោយបទពីរបីខាងចុង ក៏នៅតែប្រើ ( : ) នេះជាដរាប ព្រោះបើមិនចុច អ្នកអានអាចប្រឡំអានថា គណ (គន់)៖

ពាក្យដែលធ្លាប់ប្រើ

គណៈសង្ឃ, គណៈបក្ស, គណៈកម្មការវប្បធម៌, គណៈរដ្ឋមន្ត្រី, គណៈបេសកកម្ម, គណៈប្រតិភូ ៗ

៣– យុគលពិន្ទុនេះ មានប្រើក្នុងពាក្យខ្លះៗដែរ តែត្រូវអានឲ្យមានសូរខ្លីកញ្ចក់៖

ទេៈ, ហឹៈ, ហោៈ, ហៃៈ ៗ

៤–កុំចុចសញ្ញា (:) នេះឲ្យមានរង្វង់មូលដូចរះមុខ (៖) ៗ

# ការហាត់សាឡើងវិញ

ចូរកែពាក្យខាងក្រោមនេះ តាមពាក្យដែលបានសិក្សារួចមកហើយ ៖

| ពាក្យខុស | ពាក្យត្រូវ |
| --- | --- |
| ផ្លូវទៅកាន់ត្រពាំង មានដើមព្រសាង់ជុះឃាង់ពាង់ពីមុខ ។ | ........................................ |
| មហាវេស្សន្តរផាផក់ និយាយថាតាផ្គូផក់ផាមនុស្សទុគ៌ត, ដំណើរអ៊ុកអ៊ាក, សាបសូន្យបាតមង់អាត់ក៏ដើរភ្ញូតកុហក់សុំទានគេដ៏គ្រប់រាប់ចណ្ណាល់ ពារលើព្រៃសុំទ្រុំមួយ ត្រូវផ្ដៃបៅបេតបុត្រហ៊ុំព័ទ្ធជិត ស្មើរនឹងក្បែរផង់ ។ | ........................................ |
| សេចក្ដីប្រម៉ាត ធ្វើឲ្យមនុស្សប្រាសបាកស្នារពីម៉ឹងម៉ាត់ ។ | ........................................ |
| គណាកម្មៈការអត្ថៈរៈផាតិបានប្រ-តិបត្តិការ៍ណា បំបាត់នូវស្ថានៈការ៍ណាអាប់អួរក្នុងប្រទេស ។ | ........................................ |
| ខ្ញុំក៏ដោយ អ្នកក៏ដែរ យើងមិនអាចដឹងចិត្តអ្នកដ៏ទៃឲ្យបានផាក់ផាង់-ភាប ។ | ........................................ |

# ពាក្យពិបាក

ដែលទាក់ទង់ដោយស្រៈពេញតួខ្លះ

ឥ, ឦ, ឧ, ឩ, ឫ, ឬ, ឭ, ឮ, ឯ, ឰ, ឱ, ឳ

ឥ

មានសូរបីបែបគឺ អិ, អី, អឹ

ពាក្យដែលធ្លាប់ប្រើ

ឥ អានថា អិ

ឥតមាន, ឥដ្ឋក្រាល, ព្រះឥន្ទ, ឥន្ទធនូ (ឥន-ទ: ធនូ), ឥន្ទជិត, ឥណ្ឌៀ, ឥណ្ឌូចិន, ឥន្ទនិល, ឥន្ទវង្ស, ឥន្ទ្រីយ សត្វឥន្ទ្រី, ឥរិយាបថ (អិ-រិយ៉ា-បត់) ឥន្ទវិរូឡ្ហន ឬ ឥន្ទធីរ ។

ឦ អានថា អ៊ី

ឦស្វរ, ឦស្វរនេះ ។

ឥ អានថា អ៊ិ

ឥសី, ឥស្វរ, ឥស្សរៈ, ឥធលោក, ឥណទាន, ឥទ្ធា-
នុភាព, ឥដ្ឋ, ឥដ្ឋារម្មណ៍, ឥត្ថាគារ ។

(ពាក្យបាលីទាំងអស់)

ឦ អានថា អ៊ី

ទិសឦសាន, ឦស្វរៈ, ឦសធរ, ឦស ។

( ពាក្យនេះឲ្យអានថាអីវិញៈ ឦស្វរ )

ឧ មានសូរពីរយ៉ាងគឺ អុ, អ៊ុ

ឧ អានថា អ៊ុ

ពាក្យដែលធ្លាប់ប្រើ

ឧកញ៉ា, ឧសដុត, ឧកឬអុក, ឧកហ៊ូន ។

ឧ អានថា អ៊ុ (សុទ្ធតែជាពាក្យបាលី-សំស្ក្រឹត ៖

ឧកាសៈ, ឧក្រិដ្ឋ, ឧគ្ឃោសនស័ព្ទ, ឧឡារៈ, ឧទរ, ឧបយុវរាជ, វត្តឧណ្ណាលោម, ឧតុង្គ, ឧដុង្គឧត្តម, ឧទកៈ, ឧទាហរណ៍, ឧភតោសុជាត, គោឧសភ, ខែឧសភា, ឧទុម្ពរ, ឧទ្ទិស, ឧទ្យានឬឧទ្យាន, ឧបករណ៍, ឧបការី, ឧបការៈ, ឧបជ្ឈាយ៍, ឧបត្ថម្ភ, ឧបទ្រព, ឧបនិស្ស័យ, ឧបមា, ឧបមេយ្យ, ឧរ, ឧស្សាហកម្ម, ឧឡារិក, ឧម្មត្តកពេត (ពេតឆ្កួត), ឧទ្ធរណ៍ (ឧទ្ធរ), ឧទ្ធម្ភកបត្រ ។

ឪ អានថា អ៊ូវ

ឪពុក, ឪដំ, ឪជ្រឹង, ឪណុល, ឪទិន, ឪម៉ាល់, ឪឡ, ឪឡឹក, ឪឡុង, ឪឡោក ។

ឫ អានថា រឺ

ពាក្យខ្មែរ

ឫក, ឫកពា (មារយាទ), ឫស, ឫសដី, ឫសដូង, ឫស្សី ។

ពាក្យក្លាយពីសំស្រ្កឹត

ឫក្សពារ (ថ្ងៃ៥), ឫទ្ធានុភាព, ឫសី (ផា:ឥសី), ឫទ្ធិ, ឫសីថ្ងៃសារ, ឫស្សា ៗ

ឬ អានថា រឺ

មែនឬទេ? មាសឬប្រាក់? ទៅឬមិនទៅ? ឬនឹងថាជននេះជាចោរក៏ពុំបាន។

ឭ អានថា លឺ

រឭក, រំឭក (គេសរសេរលើក, រំលឹក) ក៏ត្រូវ ៗ

ឮ អានថា លឺ

ឮឬមិនឮ? ខ្ញុំឮហើយ។

ឯ

ចំពោះពាក្យក្លាយមកពីបាលី ឬសំស្រ្កឹត អានថា អៃ ឬ អេ, តែគេច្រើនអានថា អៃ ជាង ដើម្បីកុំឲ្យពាក្យក្លាយទាំង

នោះនៅសូរតាមភាសាដើមសុទ្ធតេក៖

## ពាក្យដែលធ្លាប់ប្រើ

ឯកោ, ឯកា, ឯកជន, ឯកឧត្តម, ឯកច្ឆន្ទ, ឯកទេស, ឯកអគ្គរាជទូត, ឯកពណ៌, ឯកស័ក, ឯកអង្គ, ឯរំ, ឯកប្យ-ហារ, ឯកឯង, ឯកសណ្ឋាន, តួឯក, ល្អឯក, ឯកភាព, ឯកបុត្ត, ឯកបទ, ឯកបថ, ឯករាជ្យ, ឯកភាគ ។

## ពាក្យខ្មែរសុទ្ធ

ឯ, ឯណា, ឯណេះ, ឯណោះ, ឯង, ឯក ឬ អែក ក្អែង ។

## ឮ អានថា អឺ

ចំពោះពាក្យក្លាយពីសំស្ក្រឹត

ឮកពណ៌, ឮសូរ ។

## ពាក្យខ្មែរសុទ្ធ

### ឮដ៏

មានន័យថា ក្នុង ឬ នៅពេលនោះ : ឮដ៏កាលនោះ

—"— ឯ, នៅ : ឮដ៏អាកាស, វេហាស៍ ។

### ឲ្យ អានថា អោ្យ

## ពាក្យបាលី ឬ សំស្ក្រឹត

ឱកាស, ពធឱរស, ឱង្ការ, ឱសថ, ឱជារស, ឱដ្ឋជៈ, ឱភាស, ឱវាទ, ឱស្ឋ, ឱក ។

## ពាក្យខ្មែរសុទ្ធ

ឱ អនិច្ចា! , ឱះឱ! (អុះ-អោ), ឱន, ឱប, ឱត, ឱយ (និយមសរសេរ : ឲ្យវិញ), ឱហាត ។

ធ្វើ គានជា អៀ

មានតែមួយម៉ាត់ គឺ ឪទក ឬ ឧទក (រុក្ខជាតិដែលរស់នៅក្នុងទឹកដូចជាត្រកួន, កញ្ឆែត ជាដើម) ។

# ពាក្យពិបាក

## ដែលតាក់ដោយ ស្រះទិស្ស័យ

## ស្រះ ិ ឬស្រះ ឹ?

បើតាមសំឡេងអក្ខរវិធី ស្រះទាំងពីរនេះមានសូរផ្សេងពីគ្នាដោយឡែក តែបើតាមការសាទិយម ខ្មែរយើងច្រើនអានឲ្យមានសូរដូច ៗ គ្នាទៅវិញ ជាហេតុនាំឲ្យអ្នកស្ដាប់ច្រឡំបាន ៗ ដើម្បីជៀសវាងការស្ទាក់ស្ទើរចិត្ត ក្នុងការសរសេរស្រះ ិ ឬស្រះ ឹ នេះ គេអាចញែកវែកឃើញថា៖

### ចំពោះពាក្យខ្មែរសុទ្ធ

១ - កាលណាមាន ក, ង, ម ប្រកបខាងចុង គេច្រើនតែដាក់ស្រះ ឹ ជានិច្ច៖

ក– ទឹក, ផឹក, នឹក, ដឹក, ព្រឹក, រលឹក, ក្ដឹក, ញឹក ។ល។

ង– ទទឹង, នឹង, ដឹង, ប្រឹង, ព្រលឹង, ស្ទឹង, រឹង ។ល។

ម– ខឹម, ទឹម, ញញឹម, រលឹម, ផ្ទឹម, សឹម ។ល។

២– ព្យញ្ជនៈ ត ប្រកបចុង មានតែបីពាក្យប៉ុណ្ណោះ ដែលប្រកបទីងស្រៈ ឹ បាន៖

១. ដើមព្រលឹតឬព្រលិត, រំងឹត, ងងឹត ។

ក្រៅពីពាក្យបីម៉ាត់នេះ ត្រូវសរសេរជាស្រៈ ិ ទាំងអស់ ។

៣– កាលណាមានព្យញ្ជនៈ ច, ន, ប, ល នៅខាងចុង គេត្រូវសរសេរប្រកបស្រៈ ិ ទាំងអស់ ។

ចំពោះពាក្យក្លាយពីបាលី

កាលណាមានព្យញ្ជនៈប្រកបខាងចុងដូចជា ក, ត, ខ, ឆ, ន, ស ជាដើម ត្រូវសរសេរស្រៈ ិ ជាដរាប៖

១. ព្រះបាទធម្មិក, អនាមិក, ហេរញ្ញិក, បុគ្គលិក, ឃោសនិក, ធនិក, ចេតសិក, ខ្សារិក ។ល។ ចិត្ត, មិត្ត, វិបរិត, បណ្ឌិត, ចិត្តបណ្ណ ។ល។ កោវិទ ។ល។ ខស.

ពិធ, ពិពិភ័ណ្ឌ ។ល។ ទិស, ឧទ្ទិស, អាមិស ។ល។

ចំពោះពាក្យក្លាយពីសំស្ក្រឹត

កាលណាមាន ក្ឫ, ត្ឫ, ត្ត, គ, ប្រកបខាងចុងច្រើន តែសរសេរជាស្រៈ - ឹ ជានិច្ច ៖

១. ព្រឹក្ស, ទ្រឹក្ស, ប្រឹក្ស ។ល។ អព្យាក្រឹត្យ, សុក្រឹត្យ ។ល។ ប្រព្រឹត្ត ។ល។ ម្រឹគ ។ល។

---

កួរ ឬ គួរ ?

បឿ ឬ ជឿ ?

កៀ ឬ គៀ ?

ខ្ញុំសង្កេតឃើញថា ក នឹង គ, ខ នឹង ឃ, ច នឹង ជ, ឆ នឹង ឈ, ដ នឹង ឌ, ឋ នឹង ឍ, ត នឹង ទ, ថ នឹង ធ, ប៉ នឹង ព, ផ នឹង ភ កាលណាប្រកបជាមួយនឹងស្រៈ ួ -ឿ- ៀ តែងមានសំឡេងដូចៗគ្នា ជាហេតុនាំឲ្យអ្នកសរសេរភ័ន្ត

ប្រឡំ ។ ដើម្បីដោះស្រាយពាក្យជាគូ ៗ ដែលមានសូរដូចគ្នានេះ គប្បីអ្នកសិក្សាសង្កេតចំណាំតាមវិធីដូចតទៅ៖

ក ទឹង គ ផ្សំជាមួយស្រៈ ួ ឿ ៀ

គ មានតែ៧ពាក្យប៉ុណ្ណោះគឺ:

គួប, គួរ (គួរសម, គួរស្រប), គ្រួបៗ, គ្រួសារ, គ្រឿង, គ្រឿន, គ្រៀស (សំពប់រុំខ្ចោប) ។

ក្រៅពីនេះសុទ្ធតែជាអក្សរ ក ទាំងអស់ ។

---

ខ ទឹង ឃ ផ្សំជាមួយស្រៈ ួ-ឿ-ៀ

ឃ មានតែ៣ពាក្យប៉ុណ្ណោះគឺ:

ឃ្មួប (ទន់ឃ្មួប), ឃ្មៀងឃ្មាត, ក្របីឃ្មៀច ។

ក្រៅពីនេះ សុទ្ធតែជាអក្សរ ខ ទាំងអស់ ។

---

ប ទន់ ប៊ ផ្សំជាមួយស្រៈ ួ-ឿ-ៀ

ប៊ មានតែ១០ពាក្យប៉ុណ្ណោះគឺ :

ពាក្យបួន, បួន ឬ ជួនណា, បួប ឬ ជួប, សត្វបៀម ឬ បៀមខ្លួន, បៀរ, ប្រៀត, ប្រៀន, ប្រៀប, ប្រៀប, ហោះប្រៀវប្រែ ។

ក្រៅពីនេះ សុទ្ធតែជាអក្សរ ប ទាំងអស់ ។

---

ឆ ទន់ ឈ ផ្សំជាមួយស្រៈ ួ ឿ-ៀ

ឈ មានតែ ៩ ពាក្យប៉ុណ្ណោះគឺ :

ឈួល ឬ ជួល, ប្រឈួន, ឈៀម, ឈ្ងួកក្បាល, ឈ្ងួល, ឈ្ងួញ, ឈ្ងួយ (ហៃហាន), ឈៀស, ឈ្ងៀន ឬ ឆ្ងៀន (របៀនផ្ទះ) ។

ក្រៅពីនេះសុទ្ធតែជាអក្សរ ឆ ទាំងអស់ ។

---

ដ ទឹង ឌ ផ្សំជាមួយស្រៈ ួ-ឿ-ៀ

មានតែពាក្យ ដ ប៉ុណ្ណោះ, ខាង ឌ មិនមានទេ ។

ប ទឹង ព មិនមានស្រៈ ួ-ឿ-ៀ ផ្សំជាមួយទេ ។

ណ ទឹង ន ផ្សំជាមួយស្រៈ ួ-ឿ-ៀ

មានតែពាក្យ ន ប៉ុណ្ណោះ, ខាង ណ មិនមានទេ ។

ត ទឹង ទ ផ្សំជាមួយស្រៈ ួ-ឿ-ៀ

ទ មានតែ ១៣ ពាក្យប៉ុណ្ណោះគឺ :

ទួល, ទៀង, ទៀត, ទៀន, ដើមទៀបឬតៀប, ទួងឬទូង, ទួនឬតួន (ពាក្យជ្វាថាលោក,អ្នក), ទួទៅឬទូទៅ, ទួទ័រឬទូទ័រ, ទួញយំ, ទួម (ដែលរួមចូល), ទ្រៀស (បន្ទោះលប), ឈើទ្រៀក ។

ក្រៅពីនេះសុទ្ធតែជាអក្សរ ឰ ទាំងអស់ ។

---

ឞ ទី៩ ឃ ផ្សំជាមួយស្រៈ ួ-ឿ-ៀ

ឃ មានតែមួយពាក្យគឺ :

ប្រហឃ្លួន៍ ឬឃ្លុន៍ ។

ក្រៅពីនេះសុទ្ធតែសរសេរជាអក្សរ ឞ ទាំងអស់ ។

---

ប៉ ទី៩ ព ផ្សំជាមួយស្រៈ ួ-ឿ-ៀ

ព មានតែ ២០ ពាក្យប៉ុណ្ណោះគឺ:

ពួក, ពួច, ពួត, ពួន, ពួយ, ខ្សែពួរ, សត្វពៀក, ពៀច, ទូកពៀប, ចងពៀរ, ពួរគោ, ហើមសាច់ព្រួក, ព្រឺព្រួច, ព្រួញ, ព្រួត, ព្រួយ, ត្រីព្រួល, ព្រួសទឹក, ព្រៀនលាន, ពេញព្រៀប ។

ក្រៅពីនេះ សុទ្ធតែជាអក្សរ ប៉ ទាំងអស់ ។

---

ព និង ភ ផ្សំជាមួយស្រៈ -ឿ -ៀ

ភ មានតែ ៧ ពាក្យប៉ុណ្ណោះគឺ:

ភឿន (ភ្លើ), ភៀសខ្លួន, ភ្លួរស្រែ, ភៀរ ឬផៀរ, ភ្លួត ឬផ្លួត (គុម្ព, សំណុំ, កំភួន), ដំរីភ្លៀក, ភ្លៀន ឬ ផ្លៀន ។

ក្រៅពីនេះ សុទ្ធតែជាអក្សរ ព ទាំងអស់ ។

# ការហាត់សាឡើងវិញ

ចូរកែពាក្យខាងក្រោមនេះ តាមការសង្កេតដែលបានសិក្សារួចមកហើយ ៖

| ពាក្យខុស | ពាក្យត្រូវ |
|---|---|
| ភពនេះមានពណ៌ដូចភ្នុះទូ ។ | ................................ |
| ក្នុងភុផលោកយើង ភពមានអ្នក | ................................ |
| មានភុត្មនុភាពណាម្នាក់ អាច | ................................ |
| ផ្ដាញ់ទឹងមរណៈភាពបានទេ ។ | ................................ |
| សម្ដេចព្រះភុបៈយុវ៉ៈពជទ្រង់ | ................................ |
| ជា១ទាហរណ៍ ដ៏ភ្ដុតមដល់សទ្ធិ- | ................................ |
| ភាពសាកលលោក ។ | ................................ |
| លឺថា អ្នូពុក់ចៅកមានរកពា | ................................ |
| ដូចជាតារីស័មែនរទេ? - ខ្ញុំដូចជា | ................................ |
| មិនដែលលឺដែរ! ។ ពេលយប់ | ................................ |
| ងងិតងិតមាត់ស្ទឹង ខ្យល់បកវិង ។ | ................................ |

ទិសខាងលិច រលកខ្ពោលៗ
ពោលហក់ហឹប អង្គុយបន្ទឹប
ស្រឹបៗភ្លៀង ៗ ស្លុកព្រិកក្រុំ
ទងធ្លាក់បើលបាលដល់ដី ជន
អ្នកមានភ្នែកសុក្រិត អាចយក
មកធ្វើជា ឧទាហរណ៍ក្នុងប្រស្នា
ជីវិត ៗ

គួរឬ? បើស្រុកកើតទុក្ខ
ហើយខ្លះនាំគ្នាត្អូញយំ, ខ្លះច្រៀង
រាំ, ខ្លះជៀសខ្លួនលែងឲ្យជួប
គ្នាយ៉ាងនេះ ៗ

# ពាក្យពិបាក

## ដែលទាក់ទងដោយព្យញ្ជនៈ

### ក្មេង ឬ ខ្មេង?

យើងដឹងហើយថា ជើង ្ក, ្ម, ្ល, ្យ, ្វ, ្ស ទាំង ៦ តួនេះ អាចយកទៅធ្វើជាមួយ ក ទីង ១ បានដូចគ្នា, កាលណាអានទៅ គេឮសូរស្រដៀងៗគ្នា ជាហេតុនាំឲ្យអ្នកសរសេរកកែបែកគំនិតមិនដឹងជាសរសេរតួណាមួយៗ ដើម្បីធ្វើការដាក់សម្គាល់ក្នុងចិត្ត គប្បីអ្នកសិក្សាចំណាំពាក្យជាក្រុមៗនេះតទៅ៖

### ក្ក ឬ ខ?

ក្ក មានតែ ៥ ពាក្យប៉ុណ្ណោះគឺ:

ក្កក់, ក្កាញ់, ក្កិកក្កក់ ឬ ក្កក់ក្កិក, ក្កិច, ក្កុង ៗ

ក្រៅពីនេះ ត្រូវសរសេរ ខ ទាំងអស់ ៗ

ក្អ មានតែបីពាក្យប៉ុណ្ណោះគឺ:

ក្អេងក្អាង, កូនក្អើយ, ម្ដាយក្អេក ។

ក្រៅពីនេះ ត្រូវសរសេរជា ក្អ ទាំងអស់ ។

---

ក្ល មាន ៣២ ពាក្យគឺ:

ពេកក្លន, ក្លងប្រាក់, បាំងក្លស់, ក្លាក់បារី, ក្លាហាន, ក្លាក់ទៀន, ក្លាក់ម្ឈូល, ក្លាត់ចោរ, ក្លែងក្លាយ, ក្លារពោស, ម្ឈូលក្លាស់, ប្រទេសក្លិង្គ, ក្លិគ្រោស, ឈុំក្លិន, ក្លឹងរទូត, (ចង់ឥតគំទ្វប), សត្វក្លឹស, អម្បោះក្លុក, ក្លីប្រោក់, ដំរីក្លៀក, រោមក្លៀក, ក្លៀវក្លា, ដើរក្លេវក្លម (គឺដើរបញ្ចុះបញ្ចូលគង្ន បទអាក្រក់), ក្លែងរូប, ក្លែបខ្ទរ, ក្លែមស្រា, ក្លោងទ្វារ, មូលក្លុំ, ផតក្លុំ, ចានក្លាំ, ត្រីក្លាំងហាយ, ដើមក្លាំពាក់, ដើមក្លាំពូ ។

ក្រៅពីនេះត្រូវសរសេរជា ក្ល ទាំងអស់ ។

---

ក្ស មាន ៨ ពាក្យគឺ:

ក្សត្រ ឬ ក្សត្រិយ៍, ក្ស័យជីវិត, ក្សាន្តចិត្ត, ក្សិណនោះ, ក្សិណក្ស័យ, ក្សីរ, ក្សេត្រាធិការ, ក្សេមក្សាន្ត ។

ក្រៅពីនេះ ត្រូវសរសេរជា ខ្ស ទាំងអស់ ។

---

ក្ទ មានតែមួយពាក្យគឺ:

ដើមក្ទម្ព (ក្ទុំ) ។

ក្រៅពីនេះត្រូវសរសេរជា ខ្ទ ទាំងអស់ ។

---

ក្វ មានតែមួយពាក្យគឺ:

ក្វែន (ប្រសប់, ស្ទាត់, ជំនាញ) ។

ក្រៅពីនេះត្រូវសរសេរជា ខ្វ ទាំងអស់ ។

ចំណាំ.–១ ជើង ្ប ផ្ញើជើងបានតែនឹង តួ ក មួយ ប៉ុណ្ណោះ មិនអាចផ្ញើនឹង ខ បានទេ ដូចជា ក្បាល, ក្បោះ

ក្បាយ, ដោះក្បាំ ។ល។

២- ចំណែកជើង ្យ ធ្វើបានតែជាមួយតួ ១ ប៉ុណ្ណោះ មិនអាចធ្វើជើងទឹង ក៏ បានទេ ដូចជា ៖

ខ្យង, ខ្យល់, ខ្យាដំរី ។ល។

---

## តម្កប?

ព្យញ្ជនៈពីរនេះមានធ្វើជើង៤គឺជើង ្យ, ្ន, ្ម, ្ល ។

ត្ន មានតែមួយពាក្យប៉ុណ្ណោះគឺ:

ដើមត្នោត

ក្រៅពីនេះត្រូវសរសេរជា ថ្ន ទាំងអស់ ។

ត្ម មាន៦ពាក្យគឺ:

អាត្មា, សត្វត្មាត, ដួលត្មិល, រាយមួយត្មាន, ដួល
ត្មោល, ត្មះតិះដៀល ។

ក្រៅពីនេះត្រូវសរសេរជា ថ្ម ទាំងអស់ ។

---

ត្ល មាន៩ពាក្យគឺៈ

ពលត្លឹង, ត្លុករបាំ, ក្រុបត្លុង, មូលត្លុំ, សត្លត្លុម, ស្រឡះត្លៅ, លៀនត្លៃ, ក្រហមត្លែត, ក្អកត្លោត ។

ក្រៅពីនេះ ត្រូវសរសេរជា ថ្ល ទាំងអស់ ។

ចំណាំ.– ១ ជើង ្ល ប្រើបានតែជាមួយ ត (ត្ល) មួយប៉ុណ្ណោះ មិនអាចប្រើជាមួយ ថ បានទេ ។

២– ជើង ្អ ក៏ប្រើបានតែជាមួយនឹង ត ដែរ មិនអាចប្រើជាមួយ ថ បានទេ ។

---

ប ឬ ប្ត?

ព្យញ្ជនៈពីរតួនេះ មានអក្សរផ្ញើជើងពីរតួគឺ ្ដ - ្ត ។

ប្ដ មានតែ ៤ ពាក្យគឺៈ

ប្ដីប្រពន្ធ, ប្ដឹងប្ដល់, ប្ដូរជីវិត, ប្ដេជ្ញា ។

ក្រៅពីនេះ ត្រូវសរសេរជា ប្ត ទាំងអស់ ។

---

ប៉ មាន ៣២ ពាក្យ គឺ:

ប៉ក់, ប៉ត, ពោរលួចប៉ន់, ប៉ប់ឬផ៉ប់, ប៉ម, ប៉ាច់, ប៉ាញ, ប៉ាត, ត្រប៉ាង, ប៉ាច់ឬផ៉ាច់, ប៉ាយ, ប៉កៗ ឬប៉ឹកៗ, ប៉ិន, ប៉ឹម, ប៉ុក, ប៉ុង, ប៉ុង ៗ , ប៉ូនឬផ៉ូន, ប៉ួកឬផ៉ួក, ប៉េះ ៗ , ប៉ៀក ៗ , ប៉ៀវ, ប៉េងប៉ោង, ប៉េះប៉ោះ, ប៉ែកប៉ែង, ប៉ែមឬព៉ែម ៗ, ប៉ោក, ប៉ោង, ប៉ោញ ៗ , ប៉ោតឬផ៉ោត, ប៉ាំ ៗ

ក្រៅពីនេះ ត្រូវសរសេរជា ប៉ ទាំងអស់ ។

ចំណាំ.- ដើម ្អ ធ្វើដើមទីម ប៉ មានតែពីរពាក្យ គឺ ប្អូន, ប្អះ ឬ ព្អះ ។

ក្រៅពីនេះ ដើម ្យ, ្អ ត្រូវសរសេរជា ប្យ, ប្អ ទាំងអស់ ។

---

## ព ឬ ភ?

ដើម ្យ ប្រកបតែជាមួយទីម ព (ព្យ) មួយប៉ុណ្ណោះ

ដូចជា ៖

ព្យាធិ, ព្យាបាល, ព្យាយាម, ខ្យល់ព្យុះ, ព្យួរ, ព្យញ្ជនៈ, ព្យាង្គ ។ល។

ឯជើង ្ឈ ត្រូវប្រកបជាមួយតួ ក (ក្ឈ) វិញ មិនអាចប្រកបនឹងពបានទេ ដូចជា ក្ឈួរស្រេ, ក្ឈិត, ក្ឈុំ, ក្ឈាំ ។ល។

---

## ពិ ឬ ពី?

ជាញឹកញយណាស់ ដែលអ្នកសិក្សាច្រឡំពាក្យពីរម៉ាត់នេះ ។ ចូរធ្វើការសង្កេតដូចតទៅ ៖

## ពិ

ពាក្យដែលមាន ពិ នៅខាងដើម ច្រើនតែក្លាយមកពីបាលីឬសំស្ក្រឹត ដែលមានរូបសព្ទដើមជា វិ (ផ្លាស់ វ ជា ព)

ពាក្យដែលធ្លាប់ប្រើ

ពិចារណា, ពិគ្រោះ, ពិបាក, ពិនិត្យ, ពិនិស្ស័យ,

ពិឃាត, ពិការ, ពិចិត្រ, ពិន័យ, ពិតាន, ពិសាខ, ពិធី, ពិសោធ, ពិពេធ, ពិទ័ត្ថ, ពិទូរ្យ, ពិន្ទុ, ពិទ្យាធរ, ពិជ័យ, ពិជិតមារ, ពិពិធភ័ណ្ឌ, ពិណ, ពិណពាទ្យ, ពិផាត, ពិពឌ្ឍសញ្ញា ឬ ពិភុទ្ធសញ្ញា, ពិភក្តិ, ពិពណ៌នា, បុណ្យពិ-ព័រណ៌, ពិព្យាយាម, ពិភាក្សា, ពិមល, ពិមាន, ពិម្ពា, ពិរាល័យ, ព្រះពិរុណ, ពិរុទ្ធ, ពិភព, ពិទ្យា, ពិស, ពិស្ណុការ, ពិសេស, ពិសម័យ, ពិសិដ្ឋ, ពិសុទ្ធ, ពិស្តារ ។

## ពាក្យខ្មែរសុទ្ធមានប្រើដោយតិច

ពិដោរ (ក្លិន), ពិត, ពិតពិល, ពិន (ស្នៀតសក់ ឬ ថែបហាលថ្នាំ), ត្រីពិទ្ធង៍, ពិល, ពិលាប (ខ្សឹកខ្សួល ឬ ឈ្មោះភ្លេងមួយបទ) ។

## ពី

ច្រើនប្រើចំពោះតែពាក្យខ្មែរសុទ្ធប៉ុណ្ណោះ ហើយមានដោយតិចតួច៖

មកពីណា?, ធ្វើពីអ្វី?, អំពី, ពីព្រោះ, ពីកេះ, ពីង (ចូងី), ពីងពង់, ពីងពាង, ពីងពាំង, ពឹមពើម, ពីរបី ៗ

ចំណាំ.- ពាក្យដាក់បានពីរយ៉ាងគឺ៖

ពិសា ឬពីសា, ពិសី ឬពីសី ៗ

# ការហាត់សាឡើងវិញ

ចូរកែពាក្យខាងក្រោម តាមការចំណាំដែលបានសិក្សារួចមកហើយ

| ពាក្យខុស | ពាក្យត្រូវ |
| --- | --- |
| ក្មេងក្មេរសព្វថ្ងៃ ចិត្តក្លាហានព្រៃ | |
| មិនបេះខ្វិកក្អក់ ធ្វើឫកឡេវខ្វា មិន | |
| មានគក់ម៉ក់ ផ្លាស់ចិត្តអាក្រក់ ក្រក្វក់ | |
| ចោលអស់ ។ | |
| ចោរលួចចោរផ្លន់ចិត្តមិនតូច អា | |
| ចោរខិលខូចលួចទាំងថ្ងៃ´ អាបើបាប់ | |
| បានមុខងាខ្វ័យ យីអាចព្រៃ | |
| ប្លោះផ្លោងផ្លូច ! ។ | |
| ផ្លូវណាមិនធ្វើឲ្យថងតឹងចិត្តភ្អះប្អូន | |
| នោះប្រាកដជាផ្លូវរបស់បង ! ។ | |
| បុណ្យពីព័រណាណ៍ល្អពិចិត្រ ឆ្បិត | |
| ពីសេស អ្នកណាអេះ បេះពាក់តែង | |
| ស្តែងរបនា គិតពីសោធយ៉ាងពីសុទ្ធ | |
| ផុតពីការណ៍ គួរទស្សនាយក | |
| ទស្សនះដាក់ក្នុងខ្ជួន ។ | |
| ហៃកៃរពីសី ពិព្រោះហេតុអ្វី បាន | |
| ផាពីឈាប ? | |

# ពាក្យពិបាក

## ដែលទាក់ទងដោយសព្ទវេយ្យាករណ៍

### នូវ ផ្ង នៅ?

ខ្ញុំតែងឃើញអ្នកសិក្សាខ្លះ សរសេរច្រឡំពាក្យជារឿងនុះនេះ ។ កំហុសនេះ កើតមកពីការយល់មិនច្បាស់នូវអត្ថន័យរបស់ពាក្យ ។ បើអ្នកសិក្សាប្រើការសង្កេតតាមវិធីខាងក្រោមនេះ៖

### នូវ

ជាអាយតនិបាតទី២ បង្អុលសេចក្តីឆ្ពោះទៅរកកម្មបទ (complément direct) ។ ប្រើបានតែជាមួយនឹងសកម្ម-កិរិយា (verbe transitif) ប៉ុណ្ណោះ ។

ឃ្លាដែលគេធ្លាប់ប្រើ

ខ្ញុំសូមថ្លែងនូវអំណរគុណដ៏ជ្រាលជ្រៅចំពោះលោក ។

សូមលោកទទួលនូវសេចក្តីរាប់អានដ៏ស្មោះអំពីខ្ញុំ ។

ខ្ញុំសូមថ្លែងនូវសេចក្តីសរសើរជាអនេកចំពោះលោក ។

ខ្ញុំសូមជូនជាប់មកជាមួយនេះនូវបញ្ជីរាយនាមពីរច្បាប់ ។

សូមលោកទទួលនូវប្រាក់ចំនួន ១០០០រៀលអំពីខ្ញុំ ។

សូមលោកទទួលនូវកតញ្ញុតាគុណនឹងមេត្រីភាពអំពីខ្ញុំ ។

សិស្សណាមានព្យាយាម សិស្សនោះគង់បានទទួលនូវលទ្ធផល ជាទីគាប់ចិត្តមិនខាន ។

ចំណាំ.— កាលណា មានប្រយោគដូច្នេះ ត្រូវធ្វើសំ-នួរក្នុងចិត្តថា : អ្វី ? ធ្វើអ្វី? ឲ្យអ្វី? ទទួលអ្វី?

វិធីប្រើពាក្យ «នូវ».— ខ្មែរយើងនិយមប្រើពាក្យ «នូវ»នេះ ដោយយកលំនាំតាមការបកប្រែផ្ទាល់នៃភាសាបាលី ត្រង់អាយតនិបាតទី២ (ំ=ប្រែថានូវ...) ។ ដូចជា «បុគ្គលោ រីបុគ្គល, ករោតិ ធ្វើ, បាបំ នូវបាប» ។ ការបកប្រែផ្ទាល់ពីភាសាបាលីមកជាខ្មែរបើមានកម្ម (complément)

ទទួលសកម្មកិរិយា តែមិនប្រែថា «នូវ» ជាដរាប តែវេលាប្រែយកសេចក្តីវិញ លោកតែងកាត់ចោលខ្លះ ៗ ចំពោះភាសាខ្មែរយើងក៏ច្រើននិយមតាមភាសាបាលីដែរ ហើយយកមកប្រើជាញឹកញាយ ៗ តែការប្រើនេះ, ក្រៅពីការថ្លែងសុន្ទរកថា ឬ បាឋកថា ឬ ក៏ធ្វើសន្និសីទ, ខ្មែរយើងមិននិយមប្រើក្នុងភាសានិយាយធម្មតាផងទេ គេប្រើតែក្នុងភាសាសរសេរប៉ុណ្ណោះ ៗ ក្នុងភាសាសរសេរនេះទៀតសោត ក៏គេមិនមែនចេះតែប្រើគ្រប់តែពាក្យ សាមញ្ញទាំងអស់នោះទេ គេច្រើនប្រើតែប្រយោគណាដែលមានសកម្មភាពថ្លៃថ្នូរ (ដូចឃ្លាខាងដើម)ប៉ុណ្ណោះ ៗ

គេមិនដែលសរសេរថា:

«ខ្ញុំទទួលទាននូវបាយ, ផឹកនូវទឹកកក, ពាក់នូវធ្មេញ, ជក់នូវបារី រួចទៅធ្វើនូវការ» ដូច្នេះទេ ៗ

## ដោយទូរ (ដោយសារ)

ជាឈ្មោះគុណនិបាតទី ៣ ។ គេច្រើនប្រើក្នុងស័ព្ទសាសនា ដែលមានន័យថា «ដោយសារ» ឬក្នុងទីបញ្ចប់រឿងនៃប្រយោគបូកណា ដែលមានន័យថា «ដល់» ។

១. ព្រះពុទ្ធត្រាស់រឿងដោយទូរ គេជ: ។

– ក៏ចប់បរិបូណ៌សម្គួរ ដោយទូរវេលានេះឯង ហោង ។

ចំណាំ.– កាលណាមានប្រយោគ ដែលមានពាក្យដោយ នៅខាងដើមដូច្នេះ ត្រូវធ្វើសំនួរក្នុងចិត្តថា: ដោយសារអ្វី? ដល់អ្វី? ។

---

## ទូរ (ហើយនឹង, ព្រមទាំង)

ជានិបាតស័ព្ទ ។ គេច្រើនឃើញទូរជានិបាតស័ព្ទនេះ ក្នុងប្រយោគបូកណា និយាយពិតការរៀបរប់ឈ្មោះព្រឹក្សា, សត្វ

ទីងឈ្មោះនាម៉ឺនមុខមន្ត្រី ដែលមានន័យថា «ហើយទីង, ព្រមទាំង» ៖

១. គគីរខ្ទង់ត្បែង ទូវធ្លឹកសុក្រំ ។ល។,

សត្វបក្សាបក្សី ទូវអស់ម្រឹគីម្រឹគា ។ល។,

ព្រះរាជវង្សានុវង្ស ទូវអស់នាម៉ឺនសព្វមុខមន្ត្រី ចៅជិត ចៅចម ជំទាវខុនណាង ។ល។

ចំណាំ .– កាលណាមានប្រយោគដូច្នោះ ត្រូវធ្វើសំនួរក្នុងចិត្តថា ហើយទីងអ្វី? ព្រមទាំងអ្វី? ។

---

## ...នីទៅទូវ (ដោយ)

គេច្រើនឃើញក្នុងប្រយោគបុរាណនិយាយពីការរៀបរាប់ឈ្មោះវត្ថុ, ព្រឹក្សា ឬពីការលាយឡំដោយវត្ថុអ្វីមួយក្នុងចំណោមវត្ថុច្រើន ដែលមានន័យថា «ដោយ» ៖

១. គ្រាលទីទៅទូវកម្រាលចៀមចំព្រែព្រំ ។ល។

– ដ៏ប្រដាប់ទីទៅនូវឈើផងទាំងឡាយ ដ៏វិចិត្រនូវផ្លែផ្កានោះផ្សេងៗ ដ៏ប្រគបទីទៅនូវបេកស្នែង បេកដងខ្វែង ៗលៗ

– ចៅបេតបុត្រ លុះឮមាត់តាជូជកទ្រហោយំ ប្រទំទីទៅនូវសំឡេងក្តែកព្រុស ៗលៗ

ចំណាំ.– «នូវ» ក្នុងប្រយោគដូចខាងលើនេះ តែងមានពាក្យ «ទីទៅ» នៅជាប់ពីខាងដើមជាដរាប ទុកជាគ្រឿងសំគាល់ដល់អ្នកសិក្សាយ៉ាងងាយ ៗ គប្បីអ្នកសិក្សាធ្វើសំនួរក្នុងចិត្តថា ទីទៅដោយអ្វី?

---

## ទៅ

ជាកិរិយាសព្ទ បង្អុលសេចក្តីឆ្ពោះទៅរកកម្ម ជាទីកន្លែងនឹងពេលវេលា (complément de lieu et de temps) ៗ ប្រើបានចំពោះតែកម្មជាទីកន្លែងនឹងពេលវេលាប៉ុណ្ណោះ៖

៩. កុមារនេះ កាលដើមឡើយមានស្រុកកំណើតនៅព្រៃវែង ឥឡូវនេះមករៀននៅវិទ្យាល័យស៊ីសុវត្ថិក្រុងភ្នំពេញ ។

– នៅពេលមានអគ្គិភ័យម្តង ៗ មនុស្សឥតទីលំនៅតែងបានទទួលនូវព្រះរាជអំណោយអំពីព្រះបិតាឯករាជ្យ ។

ចំណាំ.– កាលណាមានប្រយោគដូច្នេះ ត្រូវធ្វើសំនួរក្នុងចិត្តថា: ឯណា ? ទីណា ? ពេលណា ? ក្នុងអ្វី? ពេលអ្វី?

## ការប្រែប្រួលរវាងគុណនាមនិងនាម

មានពាក្យខ្លះ ដែលក្លាយមកពីបាលីនិងសំស្ក្រឹតមែន ផ្លាស់ប្តូរជានិច្ច រវាងនាមនិងគុណនាម ។ ពាក្យទាំងនោះមានប្រើដោយតិចបំផុតក្នុងភាសាខ្មែរ ។

## ពាក្យដែលធ្លាប់ប្រើ

| គុណនាម | ប្រែប្រួលទៅជា | នាម |
|---|---|---|
| អព្យាក្រឹត (neutre) | „ | អព្យាក្រឹត្យ, អព្យាក្រឹតភាព (neutralité) |
| ឯករាជ (Indépandant) | „ | ឯករាជ្យ, ឯករាជភាព (Indépendance) |

១. គុ. កម្ពុជា ជាប្រទេសប្រកាន់នយោបាយអព្យាក្រឹត ។ ប្រទេសអព្យាក្រឹតអាចធ្វើឲ្យមានសេចក្ដីសុខសាន្តដល់សកលលោក ។ ន. អព្យាក្រឹត្យ នៃប្រទេសខ្មែរជាកំឡាំងដល់សន្តិភាពក្នុងលោក ។

១. គុ. ប្រទេសឯករាជ ។ កម្ពុជា ជាប្រទេសឯករាជ-អព្យាក្រឹត ។ ន. ឯករាជ្យនៃប្រទេសខ្មែរបានមកដោយសារព្រះហស្តនៃសម្តេចព្រះនរោត្តម-សីហនុ ព្រោះហេតុនោះ ទើបប្រជាជនខ្មែរថ្វាយនាមព្រះអង្គថា "ព្រះបិតាឯករាជ្យជាតិ" ។

ចំណាំ - កុំប្រើ «ព្រះបិតាឯករាជ្យ» ជានាម ព្រោះគេអាចនិយាយថា «ព្រះបិតានៃឯករាជ្យ» (Père de l'Indépendance) ។

---

## ការប្រែប្រួលរវាងកិរិយានឹងនាម

ក្នុងភាសាខ្មែរ គេសង្កេតឃើញថា មានពាក្យខ្លះដែលក្លាយមកពីបាលីនិងសំស្ក្រឹត តែងមានការប្រែប្រួលជានិច្ច ។ ចំពោះពាក្យខ្មែរសុទ្ធ មិនមានការប្រែប្រួលទេ ។

ពាក្យដែលធ្លាប់ប្រើ

| កិរិយា | ប្រែប្រួលទៅជា | នាម |
|---|---|---|
| ច្បាស់ | » | ការច្បាស់ |
| និមន្ត | » | ការនិមន្ត |
| បដិវត្ត | » | ការបដិវត្តន៍ |
| ប្រព្រឹត្ត | » | ការប្រព្រឹត្តិ |
| បរិសុទ្ធ | » | សេចក្តីបរិសុទ្ធិ |

| | | |
|---|---|---|
| បញ្ញត្ត | ប្រែប្រួលទៅជា | សេចក្តីបញ្ញត្តិ |
| ប្រសូត | ,, | ការប្រសូតិ |
| ប្រវ័ត្ត | ,, | ការប្រវ័ត្តន៍ |
| ពិសោធ | ,, | ការពិសោធន៍ |
| វិវឌ្ឍ | ,, | ការវិវឌ្ឍន៍ |
| អនុវត្ត | ,, | ការអនុវត្តន៍ |
| អនុញ្ញាត | ,, | សេចក្តីអនុញ្ញាតិ |
| សន្មត | ,, | សេចក្តីសន្មតិ |

ចំណាំ.- ដើម្បីសំគាល់ឲ្យដឹងថាពាក្យទាំងនោះជានាម ខ្មែរយើងតែងដាក់ស័ព្ទថា ការ, សេចក្តី, ដំណើរ, កិរិយា នៅពីខាងដើមពាក្យទាំងនោះ (ការអនុវត្តន៍) ។ ឯស័ព្ទដែលគេប្រើញឹកញាប់គឺ ការ, សេចក្តី ។ ដូច្នេះគប្បីអ្នកសិក្សាតាមសង្កេតមើល បើកាលណាឮស័ព្ទទាំងនេះនៅខាងដើមពាក្យទាំងនោះប្រាកដជានាមហើយ ។

# ការហាត់សាឡើងវិញ

ចូរកែពាក្យខាងក្រោមនេះ តាមការបង្កេតដែលបានសិក្សារួចមកហើយ

| ពាក្យខុស | ពាក្យត្រូវ |
| --- | --- |
| សូមលោកទទួលនៅអំណរគុណជាមុន ព្រមទាំងសេចក្ដីរាប់អានដ៏ស្មោះអំពីខ្ញុំ ។ | |
| ព្រលឹមឡើង ផ្សារថ្មីគេឃើញមនុស្សប្រុសស្រីនៅក្មេងតូចធំ ដើរអ៊ូអរចុះឡើង ខ្លះមានកាន់នូវដៃ នៅកញ្ចប់តូចធំនំនែក ដើម្បីយកទៅចែកជាយអ្នកនូវផ្ទះ ។ | |
| សម្ដេចព្រះបិតាឯករាជជាតិ ទ្រង់ដឹកនាំនាវាអព្យាក្រឹត្យ ឆ្ដោះទៅកាន់ត្រើយសន្តិភាព ។ | |
| ការអនុវត្តមាគ៌ាអព្យាក្រឹត្យ នាំឲ្យនាវាកម្ពុជាឃ្លេងឃ្លោងអណ្ដងអណ្ដល ព្រោះតែការប្រព្រឹត្តអំពើស្មោកគ្រោកនៃជនអ្នកនៅជិតខាង ។ | |

# ពាក្យពិបាក

## ដែលទាក់ទងដោយសទិសស័ព្ទ

ដូចអ្នកសិក្សាបានដឹងមកហើយថា "ការសិក្សាអនុពាក្យ" ជាដំបូង តោងសិក្សាអំពីការអានឲ្យត្រឹមត្រូវទឹង ការសរសេរត្រូវអក្សរឲ្យបានច្បាស់លាស់តាមអក្ខរវិធី, ជាបន្ទាប់ តោងសិក្សាអំពីពាក្យពិបាកដែលទាក់ទងដោយវណ្ណយុត្តិខ្វះ, ដោយស្រះពេញតួ, ដោយស្រះទិស្ស័យ, ដោយព្យញ្ជនៈ ទឹងដោយស័ព្ទវេយ្យាករណ៍ ឃើញថា "ការសិក្សាអនុពាក្យ" យើង មានគ្រឿងឧបករណ៍ស្ទើរតែគ្រប់គ្រាន់ដែរហើយ ប៉ុន្តែខ្ញុំសង្កេតឃើញនៅមាន "ពាក្យពិបាកដែលទាក់ទងដោយសទិសស័ព្ទ" មួយទៀត ដែលតែងធ្វើកិច្ចកលនាំឲ្យអ្នកសិក្សាភ័ន្តមង ៗ ស្ទើរតែគេចពីកំហុសមិនរួច ពីព្រោះក្នុងភាសាខ្មែរយើងក៏ដូចជាភាសាបារាំងដែរ គឺមានពាក្យច្រើនណាស់ដែលអានដូច ៗ គ្នា

តែបែរជាមានន័យផ្សេងគ្នាទៅវិញ ។

ហេតុនេះ បើចង់ជៀសវាងកុំឲ្យមានការស្ទាក់ស្ទើរចិត្ត ឬក៏ទ្ទច្រឡំតទៅទៀត គប្បីអ្នកសិក្សាឆ្លៀតពេលសង្កេត-ពិនិត្យ - ចំណាំនូវសទិសសព្ទទាំងនេះ ឲ្យបានជាក់ច្បាស់ក្នុងចិត្តដូចតទៅ ៖

## សទិសសព្ទក្នុងព្យញ្ជនៈ «ក»

ក. ន. កមនុស្ស

ក៏ និ. អ្នកក៏ដោយ

ការ ន. ដៃ: លើកការប្រណម្យ

ការ ន. កម្មករ, ពលករ, វិស្វករ, ឃាតករ, ធាតុករ, វិចិត្រករ, កសិករ, និករ, និសាករ (ព្រះចន្ទ), មករ, ឧស្សាហករ, ហត្ថករ ។

ករណ៍ ន. ឧបករណ៍, វេយ្យាករណ៍, អធិករណ៍, ខេត្តុប្បករណ៍, សិក្ខុប-ករណ៍, នេសាទុប្បករណ៍, សហករណ៍ ។

កករ ន. កករទឹក ។

កណ្ឌ ន. សស្ត្រាមួយកណ្ឌ

កន្លះ គុ. កន្លះម៉ោង

កាប ន. កាបរទេះ

កប្ប ន. មួយកប្ប

កម្ម ន. កម្មផល, អំពើ

កល ន. កិច្ចកល, ឧបាយ

កល្ប ន. មួយកល្ប

កាល ន. ពេល

កា ន. បំពង់ដាក់ទឹក

ការ ន. ធ្វើការ, កម្មការ
អធិការ, ពលិការ

កាណ៌ ន. ព្រះកាណ៌
(ត្រចៀក)

កាន់ កិ. កាន់វត្ត

កន្លាស់ ន. កន្លាស់ក

កាព្យ ន. ពាក្យកាព្យ

កាប់ កិ. កាប់ចាក់

កាំ ន. កាំជណ្ដើរ

កល់ កិ. កល់កង់ឡាន

កាល់ កិ. គោកាល់ញី

កាឡកណ្ណី ន. មនុស្សចង្រៃ

កា កិ. កាស្រោមសំបុត្រ

ការ ន. ការងារ, ការពារ
លេខាធិការ, ទិន្នាការ

ការណ៍ ន. (ហេតុ) ព្រឹត្តិការណ៍,
គោលការណ៍, អត្ថការណ៍,

ក្រៃ ន. និយាយគេរគេ ក្រើ្ន ន. គ្រើមតិក

ក្រោត គិ. គោតក្រែន ក្រោដិ ប.ស. ចំនួន ១០ លាន

ក្រោឌ្ឋ ន. គោដ្ឋដាក់ធាតុ

ក្រិត គិ. ក្រិតចំណាំ ក្រឹត្យ ន. ក្រឹត្យវិន័យ

សទិសសំពួគ្នា ជព្យញ្ជនៈ "ខ"

ខណ្ឌ ន. ខេត្តខណ្ឌ, ខណ្ឌសីមា ខន្ធ ន. រំលត់ខន្ធ,

ក្រុបខណ្ឌ, ខណ្ឌជញ្ជាំង វិញ្ញាណក្ខន្ធ

ខាន់ ន. ព្រះខាន់

ខ្វួ ន. ខ្វួក្បាម, ខ្វួបង្អង់ ខ្វៀវ ន. ខ្វួរក្បាលមនុស្ស

ខៀ ន. ខៀវ ខៀវ ន. ស្វាខៀវ

## សទិសស័ព្ទក្នុងព្យញ្ជនៈ "គ"

គ គុ. មនុស្សគថ្លង់

គរ ន. ដើមគរ, គរជាគំនរ

គណ ន. សិស្សគណ

គន់ កិ. គយគន់

គុណ ន. គុណមាតាបិតា

គុន ន. គុនដាល់

គុំ កិ. គុំរាយគ្នា

គុម្ព ន. គុម្ពឈើ

គូ ន. មានមួយគូ(ពីរ)

គូរ កិ. គូរគំនូរ, គិតគូរ

គេ បុ. គេឯង, ពួកគេ

គេហ៍ បុ. ស្រីមេផ្ទះ

("ឃ" គ្មានសទិសស័ព្ទទេ)

## សទិសស័ព្ទក្នុងព្យញ្ជនៈ "ង"

ង គុ. ទូកង

ងរ កិ. ងរចុះងរឡើង

ងា កិ. ងាដៃជើង

ងារ ន. ការងារ, ដីមួយងារ

## សទិសស័ព្ទក្នុងព្យញ្ជនៈ "ប"

ប ន. ឆ្នាំប

បរ កិ. គ្រាប់បរ, គោបរ, ចកបរ

បក្រ ន. បក្រយាន, ពេជ៍ បក្រ, អាណាបក្រ, ពុទ្ធបក្រ,

ចាក់ កិ. ចាក់ទឹក, ចាក់សម្រាម, មនុស្សចាក់គ្នា

ប័ណ្ណ គុ. ប្រច័ណ្ឌ

បន្ទ ន. ព្រះចន្ទ

បន្ទន៍ ន. ខ្លឹមចន្ទន៍

...ប័ន្ទ ន. ទំព័ក្កប័ន

បារ ន. ផ្កាចារ

បារ កិ. ចារសស្ត្រា

បារ្យ ន. អាចារ្យ, អនាចារ្យ អស្ចារ្យ, ព្រឹទ្ធាចារ្យ

បារុ៍ ន. ពាក់ចារុ៍, ចារុ៍មាស - ចារុ៍ប្រាក់

បិត កិ. ចិតបន្លែ

បិត្ត ន. ចិត្តល្អអាក្រក់

បិត្រ ន. ចិត្រមូលភ្លើង, វិចិត្រ

ហោត គុ. ប្រាំងទទេហោត  ហោឋ ន. ហោទឆ្ងើយ

ប្បា ន. ផ្កាប្បាតតកុំន  ប្បារ ន. សួនប្បារ,

## សទិសសព្ទក្នុងព្យញ្ជនៈ «ឆ»

ឆន្ទ ន. កាព្យឆន្ទ  ឆាន់ កិ. និមន្តលោកឆាន់

ឆ្មា ន. សត្វឆ្មា  ឆ្មារ គុ. សរសៃឆ្មារ, តូចឆ្មារ

## សទិសសព្ទក្នុងព្យញ្ជនៈ «ជ»

ជន ន. នរជន  ជន់ កិ. ទឹកជន់លិច

ជន្ម ន. ព្រះជន្ម

ជាត គុ. ដែលកើតហើយ  ជាតិ ន. ជាតិខ្មែរ

ជួ គុ. មនុស្សជួជាតិ

ជួរ ន. ឈរជាជួរ, ជួរខាងម្ដាយ

ជុំ កិ. វិ. មួយជុំ

ជំ ន. ជំទុំជំរះ, ជំនះ

(«ឈ, ញ» គ្មានសទិសសព្ទទេ)

សទិសសព្ទក្នុងព្យញ្ជនៈ «ដ»

ដ ន. កំពង់ដ, ទូកដ

ដរ គុ. ដំបៅដរ, បូសដរ

ដ៏ និ. ដ៏ប្រសើរ

ដា ន. ថ្នា (ថ្នំ)

ដារ ន. ធ្វើបុណ្យដារ

ដុស កិ. ធ្វើឲ្យជ្រះ=ដុស ធ្មេញ, ដុសខាត់, ដុសខោអាវ

ដុះ កិ. ធ្វើឲ្យច្រើនឡើង=ស្រូវ ដុះ, ពោះដុះ, ដីដុះ

(ឋ, ឌ, ឍ, ណ, ត, ថ គ្មានសទិសសព្ទទេ)

សទិសសព្ទក្នុងព្យញ្ជនៈ «ទ»

ទ ន. ទឹកហូរតាមទ

ទ្រ កិ. (ពាក្យជេរ)

ទន្ត ន. ព្រះទន្ត (ធ្មេញ)   ទាន់ ក. ដើរទាន់

ទា ន. សត្វទា   ទារ ក. ទារថ្លៃផ្ទះ

ទាល់ ន. ដើមទាល់, ទាល់ច្រក   ទ័ល គុ. ទ័លក្រ, អ្នកទ័លក្រ

ទុក ក. ទុកដាក់, ទុកចិត្ត   ទុក្ខ ន. កើតទុក្ខ, ទុក្ខវេទនា

ទូ ន. ទូដាក់ខោអាវ   ទូរ ក. ទូរទាត់, ទូរគ្នា, ទូរស័ព្ទ

ទោស ន. គុណទោស   ទោះ ធ. ទោះជាយ៉ាងណាក៏ដោយ

ទុំ គុ. ផ្លែឈើទុំ, ចាស់ទុំ   ទំ ក. សត្វទំលើមែកឈើ

## សទិសសព្ទក្នុងព្យញ្ជនៈ "ធ"

ធន ន. ធនធាន, ទ្រព្យធន   ធន់ ក. ធន់ទ្រាំ, អត់ធន់

ធុន ន. មនុស្សមួយធុន
    បានមួយធុន

ធុំ កិ. ធុំក្លិនក្រអូប
ធំ គុ. តូចធំ, ឪពុកធំ

## សទិសស័ព្ទក្នុងព្យញ្ជនៈ “ន”

ន៎! និ. នុ៎ះន៎!
នរ ន. នរជន

នប់ គុ. ស្នែងក្របីកន្ទប់
នព្វ ប.សំ(៩), នព្វន្ត, នព្វគុណ

ន័យ ន. ន័យនៃពាក្យ
នៃ អាទិ. ធនាគារជាតិនៃកម្ពុជា

នាដ ន. នាដករ
នាថ ន. នាងនាថធីតា

នូវ អាទិ. បានទទួល
    នូវអំណោយ
នូវ និ. នូវអស់នាម៉ឺនសព្វមុខ
    មន្ត្រី

ណៅ ក. នៅឯណា?

ណុះ សព្. អ្នកណា នុះ?

ណោះ វិ. ស. នុះនោះ

សទិសសព្ទក្នុងព្យញ្ជនៈ "ប"

បង់ក ក. បង់កកន្ទ្រង

បង្ក ក. បង្កហេតុ

បត់ ក. បត់សំពត់

បទ ន. បទចម្រៀង, ធ្វើបទ

បបិ ន. (ផ្ទរ) ផលបថ

បា ប. ហៃបាអើយ, គោបា មេបា

បារ ក. បារកកាយ, បារអង្ករពីត្បាល់

បាត ន. បាតឆ្នាំង, បាតដី, បាតខ្ទះ, បាតដៃ, បិណ្ឌបាត

បាទ ន. (ជើង) ព្រះបាទ, ឆ្លើយបាទ

បាត្រ ន. បាតដែក, គ្របបាត្រ

បាទុក ន. សុពណ៌បាទុក (ស្បែកជើងមាស)

បាត់ កិ. បាត់អីវ៉ាន់

ប័ត្រ ន. សញ្ញាប័ត្រ, វិក័យប័ត្រ

បិត កិ. បិតឈើសម្រួប

បិទ កិ. បិទទ្វារ, បិទមាត់

បុស្ស ន. ខែបុស្ស

ប៉ុះ កិ. ប៉ុះអណ្ដៅ, គោប៉ុះ

ប្អូ ន. បងប្អូ

ប្អូរ កិ. និយាយបូរបាច់

ប្អូណ៌ គុ. បរិបូណ៌

ប្អូព៌ គុ. ទិសបូព៌

ប្រមាទ កិ. ធ្វេសប្រហែស

ប្រមាថ កិ. មើលងាយ

ប្រយ័ត គុ. កិ. មនុស្សប្រយ័ត, ត្រូវប្រយ័តពាក្យសំដី

ប្រយ័ត្ន ន. ការប្រយ័ត្ននាំឲ្យបានសុខ

ប្រាប កិ. (ធ្វើឲ្យចុះចាញ់) ប្រាបសត្រូវ

ប្រាប្ត គុ. (បានសម្រេចហើយ)

ប្រុស បុរិស. ប្រុសស្រី

ប្រុះ គុ. ក្ងប្រុះ

ប្រោស កិ. ប្រោសសត្វ, ពានប្រោស,

ប្រោះ កិ. ប្រោះត្រី, ប្រោះអន្ទង់,

ប្រណិប័តន៍ កិ. ក្រាប ប្រណិប័តន៍ (សំពះ)    ប្រតិបត្តិ កិ. ប្រតិបត្តិតាម, ប្រព្រឹត្តតាម

បញ្ញត្ត កិ. រាជការបញ្ញត្ត    បញ្ញត្តិ ន. សេចក្តីបញ្ញត្តិ

## សទិសសព្ទក្នុងព្យញ្ជនៈ "ផ"

ផ្សា គុ. កិ. ខ្លោចផ្សា, ឈើផ្សា, ប្រែផ្សាមាត់    ផ្សារ ន. ផ្សារថ្មី, ផ្សារកណ្ដាល

## សទិសសព្ទក្នុងព្យញ្ជនៈ "ព"

ព កិ. ពកូន, ពពោះ    ពរ ន. សាធុការពរឆ្នាំថ្មី

ពង់ កិ. ក្បាកពង់, ពង់ខ្ទុះ    ពង្ស ន. ពូជពង្ស

ពន់ គុ. ពេកពន់, ពន់ប្រមាណ    ពន្ធ ន. បង់ពន្ធ, ប្រពន្ធ

ពស់ ន. សត្វពស់    ពោះ ន. ពោះមនុស្ស

ពស្តុ ន. ពស្តុតាន៍ ពស្ត្រ ន. ព្រះពស្ត្រ(សំពត់)

ពាត កិ. វិ ដាក់ពាត ពាទ្យ ន. ពិណពាទ្យ

ពាធ កិ. ពាធជន្ម, ទាពាធ(ឈើ)

ពី ន. មកពីសាលា ពីរ ប. សំ. ពីរបី

ពុត កិ.ន ធ្វើពុតជាឈឺ, ចេញពុត ពុទ្ធ ន. ព្រះពុទ្ធ

ពុធ ន. ថ្ងៃពុធ

ពេចន៍ ន. ពាក្យពេចន៍ ពេជ្ឈ ន. ពេជ្ឈឃាត

ពេជ្រ ន. ត្បូងពេជ្រ

ពៃ ន. ល្ពៃ, ប្រាក់១ពៃ ពៃរ៍ ន. ពោសពៃរ៍

ពោរ គុ. ពោរពេញ, ពុះពោរ ពោធិ ន. ដើមពោធិ

ព្រ័ត្រ ន. ព្រ័ត្រជ្រោម, កាត់ព្រ័ត្រ ព្រាត់ កិ. ព្រាត់ប្រាស

ព្រាម ន. ស្វាព្រាម ព្រាហ្មណ៍ ន. ពូជព្រាហ្មណ៍

ព្រឹក ន. ព្រឹកល្ងាច

ព្រឹក្ស ន. ពោធិព្រឹក្ស
ព្រឹក្សព្រៃ, ជម្ពូព្រឹក្ស

ព្រឹត្តិ ន. ការប្រព្រឹត្ត,
ប្រែព្រឹត្ត

ព្រឹទ្ធ គុ. ព្រាហ្មណ៍ព្រឹទ្ធ,
ចាស់ព្រឹទ្ធ, ព្រេងព្រឹទ្ធ

## សទិសសព្ទក្នុងព្យញ្ជនៈ «ភ»

ភប់ កិ. ភប់ប្រសព្វ, ភប់ភ័ន្ត

ភព ន. ភពផែនដី, ពិភព

ភក្តិ ន. មិត្តភក្តិ, ស្វាមីភក្តិ

ភក្ត្រ ន. ព្រះភក្ត្រ (មុខ)

ភ្លក្ស កិ. ភ្លក្សរស

ភ្លុក ន. ភ្លុកដំរី, ស្រះភ្លុក

## សទិសសព្ទក្នុងព្យញ្ជនៈ «ម»

មី ន. ឆាមី, មីគោក

មីរ គុ. មីរដេរដាស

មូល ន. មូលហេតុ, មូល្យ ន. ប្រាក់ខែ, ឈ្នួល

រន្ធន់មូល (ប្រើក្នុងពាក្យកាព្យបុរាណ)

មួ កិ. មួម៉ៅ មួរ ន. ស្រូវមួរ, ស្រែមួរ

ម្រ័ក្សណ៍ ន. ជ័រម្រ័ក្សណ៍ ម្រាក់ ន. ត្នើម្រាក់

ម៉ដ្ឋ គុ. សាប់ម៉ដ្ឋ ហ្មត់ កិ. វិ. ស៊ីហ្មត់, ហ្មត់ហ្មង

សទិសស័ព្ទក្នុងព្យញ្ជនៈ “យ”

យល់ កិ. យប់យន់, យន់ចិត្ត យន្ត ឬ យន្ត្រ ន. រថយន្ត

យា កិ. យាយី (បៀតបៀន) យារ គុ. (ស្រុងចុះ)

យារ កិ. យារដៃយារជើង យារ ន. សេកយារ

យាស់ ន. យាស់ជញ្ជាប់ស្លឹកស្រូវ យះ កិ. ធ្វើឲ្យរយះ

យុក ន. សត្វយុក យុគ ន. អាយុពិភពលោក

យុត្ត គុ. ត្រឹមត្រូវ    យុត្តិ ន. សេចក្ដីត្រឹមត្រូវ

យុទ្ធ ន. តយុទ្ធ

យោក កិ. ដើរយោកខ្លួន    យោគ ន. ការរួបរួម, ប្រយោគ

យោគ្យ ន. យោគ្យភាព

យោធ ន. ដំរយោធ    យោវ៌ គុ. វ័យកំឡោះក្រមុំ

យម ន. យមបាល, យមរាជ    យំ កិ. ស្រែកយំ

សទិសស័ព្ទក្នុងព្យញ្ជនៈ "រ"

រង់ កិ. រង់ចាំ    រង្គ ន. ដ័ររង្គ

រុង កិ. រុងរឿង

រងំ គុ. ភ្លេងឮធំ    រងុម ។. ឮសូររងុមៗរឿយៗ

រដ្ឋ ន. ប្រទេស, ដែន,    រត្ន ន. កែវ, ពេជ្រ, ត្បូង

រត្ត គុ. ពណ៌ក្រហម    រ័តន៍ ឬ រ័ត=ត្រ័យរ័តន៍

រថ ន. រថភ្លើង, រាជរថ　　រត់ កិ. រត់លឿន

រុត កិ. រុតត្រី

រស ន. មានរសជាតិ　　រស់ កិ. រស់ស្ងាប់

រក្ស កិ. (រក្សា) អនុរក្ស, អនុគ្រោះ　　រាក់ គុ. រាក់ជ្រៅ

រាក កិ. ឈឺពក　　រាគ ន. ភ្លើងរាគ

រាប កិ. ទឹករាបពេញស្រែ　　រាជិ ន. រាជសម្បត្តិ

រាជ្យ ន. ឯករាជ្យ

រាប គុ. រាបស្មើ　　រាពណ៍ ន. ព្រះរាពណ៍

រិស្ត ន. ដំណើរគាំទ្រក់, ចាប　　រិះ កិ. រិះរកឧបាយគល រិះគិត, អ្នករិះ

រូង្គ ន. (រូង) រន្ធគុហារ　　រុង ន. ឈ្មោះកក់ម៉ាន

វណ្ណ ន. កិរិយាយំ

វៀ កិ. វេក　　　　វៀហ៍ ន. វេហ៍ពល

វៀគ ន. ឈ្មោះឈើ, រោគ　វៀគ ន. កើតរោគ

ក្រហម

ឫក ន. ឫកពាមារយាទ　　ឫក្ស ន. ឫក្សពារថ្ងៃខែ

ឫក្សណ៍ ន. ឫក្សណ៍ការណ៍

ឫត ន. សេចក្ដីពិត　　ឫទ្ធ គុ. ឫទ្ធខ្លាំងពូកែ

រឹត កិ. រឹតខ្សែ

## សទិសស័ព្ទក្នុងព្យញ្ជនៈ «ល»

ល័ក្ក ន. ល័ក្កចាន់　　លក្ខឬលក្ស ន. សេចក្ដីកំណត់

ល័ក្ដឬល័ខ ន. ល័ក្ដក្រហម　លាក់ កិ. លាក់ឈើ

លក្ខណ៍=ស្រីគ្រប់លក្ខណ៍　លក្ស្មណ៍ ន. ព្រះរាមព្រះលក្ស្មណ៍

លង់ ក. លង់គំនិត | លុង ក. លុងឈើ

លត់ ក. លត់ភ្លើង | លុត ក. លុតជង្គង់

លុត្ត ក. លប់ពោល | លុទ្ធ ន. លុទ្ធកម្ម

លុទ្ធ ន. លុទ្ធបុគ្គល

លាប ក. លាបលន | លាភ ន. ខ្ញុំមានលាភ (បាន)

លឺ ន. ពាក្យចិនថាអ្នក | ឮ ក. ឮឬទេ ?

លូក ក. លូកដៃ | លូខ គុ. សៅហ្មង

លស់ ក. គ្រុនលស់, លស់ខាន, លស់លា | លោះ ក. លោះស្រែពីគេ, លោះស្នា, ជំលោះ

លោប ន. ការលើកពោល | លោភ ន. ការចង់បានច្រើន

លឹង ន. ពៅព្រលឹង | លិង្គ ន. (ភេទ) បុំលិង្គ

លលា គុ. ឆ្កួតលលា | លលាដ៍ ន. លលាដ៍ក្បាល

## សទិសស័ព្ទក្នុងព្យញ្ជនៈ “វ”

វ ន. ឈ្មោះយានមួយ សម្រាប់ស្តេចប្រថាប់

វគ្គ ន. មួយវគ្គ

វង់ ន. ក្រុមមួយវង់, វង់មូល

វដ្ដ គុ. សំសារវដ្ដ (វិល)

វត្ស ន. កូនគោ

វ័ធ កិ. ក្របីវ័ធ

វា បុ.ស. ពួកវាលេងកូន

វាត កិ. វាតមុខ, វាតទី

វិវិត្ត គុ. (ស្ងាត់) វិវិត្តដ្ឋាន

វារ កិ. វារហើយ ! វីវរ វារើកចេញទឹកស្ងួត

វាក់ កិ. ភ័ន្តប្រឡំ, វាក់គំនិត

វង្ស ន. ព្រះរាជវង្ស

វត្ត ន. វត្តលោក, វត្តប្រតិបត្តិ

វត្ស ឬ វត្សរ៍ ន. សតវត្ស

វាត់ កិ. វាត់សន្ទូច

វារ កិ. ក្មេងវារលេង

វាទ ន. ពាក្យពោល, ផរុស-វាទ, វិវាទគ្នា

វិវិធ គុ. (ច្រើនយ៉ាង) វិវិធ-ភ័ណ្ឌ

វិហា ឬ វិហាស៍ ន. ឋានសួគ៌, វិហារ ន. ព្រះវិហារ

អាកាស

វី កិ. វីគ្រាប់ស្រូវ    វីរ គុ. (ក្លាហាន) វីរបុរស

## សទិសស័ព្ទក្នុងព្យញ្ជនៈ «ស»

ស គុ. ពណ៌សខ្ចៅ    ស កិ. សសេចក្តី

សរ ន. ធ្នូសរ    សរ កិ. សំដីសរជាតិ

ស័ក ន. ឯកស័ក    សក្តិ ន. អ្នកមានបណ្តាសក្តិ ឋានន្តរស័ក្តិ

សាក់ កិ. សាក់ខ្លួន

សង់ កិ. សង់សាលា    សង្ឃ ន. ព្រះសង្ឃ គណៈសង្ឃ

សង្ស ន. អានិសង្ស

សង្កា ន. សេចក្តីសង្ស័យ    សង្ការ ន. សង្គ្រាម

សង្គ្រោះ កិ. (បណ្ដាល, និមិត្ត) សង្គ្រោះ ន. ការដឹកនាំ ខ្ញុំសង្គ្រោះឃើញខ្មោច

សង្គ្រា គុ. រាងសង្គ្រា
សង្គ្រារ កិ. (សម្លាប់) សង្គ្រារជីវិត

សត្ត ប.សំ. ៧
សត្វ ន. ពួកសត្វ

សត្យ ន. ពាក្យសត្យ
សាត់ កិ. សាត់ទៅវិញទៅមក

សប់ កិ. សប់គង់
សប្ដ, សប្ដិ ន. យល់សប្ដិ

សព ន. (ខ្មោច) លើកសព. សំស្ការ
សព្វ គុ. សព្វថ្ងៃ, សព្វដង សព្វគ្រប់, សព្វយ៉ាង

សម គុ. សមគ្នា
សំ ន. គ្រឿសុំសំ

សម៉ ន. ដើមសម៉
សមរ ន. សមរភូមិ

សា កិ. សាចុះសាឡើង
សា ន. សាស្រូវ

សារ ន. ជ័រសារ
សារ ន. ខ្ទឹមសារ, ឯកសារ

សៅ គុ. សម្បុរសៅ
សៅរ៍ ន. ថ្ងៃសៅរ៍

សិង ក. លោកសិង(ដេក)   សិង្ហ ន. សត្វសិង្ហ

សិត ក. សិតទឹក   សិទ្ធ គុ. សិទ្ធកម្ម

សិរ ន ព្រះសិរ (ក្បាល)   សេ ក. វិ. ដើរញាប់សេ

សើរ គុ. ឥតញញើត

សុក ន. ខន់សុក   សុខ គុ. សុខសប្បាយ

សុក្រ ន. ថ្ងៃសុក្រ

សុង ន. សូម្យសុង   សុង្ក ន. (ពន្ធ) សុង្កបរស

សូ ន. ខ្សែសូ   សូរ គុ. សូរសំឡេង, សូរភាព

សូន ក. សូនរូប   សូន្យ គុ. ស្ងាត់សូន្យ

សួ ក. សួស្ដាន   សួរ ក. សួរឆ្លើយ

សួគ៌ ន. ឋានសួគ៌

សៀ ក. លះបង់, សៀកំឡាំង   សៀរ ក. វិ. ដើរសៀរ

សេក ន. សេកសោម   សេក្ខ ឬ សេខ ន. អ្នករៀន

សេព គុ. សប្បុរស　　សេដ្ឋ គុ. សេដ្ឋកម្ម

សេស គុ. សេសសល់,　　សេះ ន. សត្វសេះ

ថ្ងៃសេស, ពិសេស　　សសេះសសោះ

សំរិត កិ. សំរិតសំកាំង　　សំរឹទ្ធ ន. ផ្តិលសំរឹទ្ធ

សាសន៍ ន. សាសន៍តាម,　　សាស្ត្រ ន. (ក្បួនច្បាប់)

ពុទ្ធសាសន៍　　ភូមិសាស្ត្រ, ប្រវត្តិសាស្ត្រ

សិះ កិ. ជាសះស្បើយ

ស្គា ន. ដើមស្គា　　ស្គាវ កិ. ពស់ស្គារគ្នា

ស្គុស គុ. សស្គុស, ស្គុសស្គាយ　　ស្គុះ ន. ដើមស្គុះ

ស្រាស់ កិ. ស្រាស់បន្ទា　　ស្រះ ន. ស្រះស្រង់

ស្រុស កិ. ស្រុសទឹកក្តៅ　　ស្រុះ កិ. ស្រុះស្រួលគ្នា

ស្មា ន. ស្មាក្តី　　ស្មាវ កិ. ស្មាលោពេស

ស្និត ន. ចេកមួយស្និត    ស្និទ្ធ ក. ស្និទ្ធស្នាលគ្នា

ស្លេះ ក. ស្លេះទុកសិន    ស្លេស្ម៍ ន. ក្អកធ្លាក់ស្លេស្ម៍

ស្មើ ក. ស្មើគ្នា    ស្មើរ ន. ម្ទូមួយស្មើរ

សទិសសព្ទក្នុងព្យញ្ជនៈ «ហ»

ហត្ថ ន. (ដៃ) មួយហត្ថ    ហាត់ ក. ហាត់ប្រាណ

ហដ្ឋ ន. ហត្ថចិត្ត (រីករាយ)

ហា ឧ. សំ. ហោរហាយ(៩), ហារ ក. លេខដើរហារ

ហា មាត់

ហៀ គុ. ស្ដើងហៀ    ហៀរ ក. ទឹកហូរហៀរ

ហោ ន. ឈើគូសមួយហោ    ហោរ ន. ហោរចេះទាយ

(«ឡ» ឥតមានសទិសស័ព្ទទេ)

## សទិសស័ព្ទក្នុងព្យញ្ជនៈ «អ»

អ ន. ប៉ុអ    អរ កិ. ត្រេកអរ

អង់ កិ. រង់ចាំ, អង់ចាំ    អង្ក ន. អង្កវិទ្យា

អង្គ ន. លោកមួយអង្គ,
ព្រះអង្គ

អង្គា ន. ដើមអង្គា    អង្គារ ន. ថ្ងៃអង្គារ

អត្ត ន. (ខ្លួន) អត្តឃាត    អដ្ឋ ប. សំ. ៨

អត្ថ ន. (សេចក្ដី) អត្ថប្រ-
យោជន៍    អឌ្ឍ គុ. (កន្លះ) អឌ្ឍមាស

អាត់ គុ. សេកអាត់    អាត់ ន. អាត់ស៊ីដ

អន់ គុ. កំឡាំងអន់    អន្ធ គុ. (ខ្វាក់) អន្ធការ

អន្ន ន. គ្រឿងបរិភោគ
អន្ត គុ. (អាក្រក់) អន្តគម្ម

អប្ប គុ. ស្តួចស្តើង
អំពូ, អំព្រ ន. អំពូវផ្សេង

អាប់ គុ. អាប់អួរ
អាប់ កិ. អាប់លុយ

អា បុ. ស. អានេះទៅណា?
អារ កិ. អារឈើ

អារ្យ ន. អារ្យធម៌
អាមិ ន. ធមិអាច់,អាច់កំប៉ាំង

អាចារ ន. ចរិយា,មារយាទ
អាចារ្យ ន. គ្រូអាចារ្យ

ឥត កិ. ឥតមាន
ឥដ្ឋ ន. ផ្ទះឥដ្ឋ,ឥដ្ឋមនុញ្ញផល

ឥណ ន. (បំណុល)ឥណទាន
ឥន្ទ,ឥន្ទ្រ ន. ព្រះឥន្ទ

ឧក កិ. បន្ទោស, ទុកបត្រង្គ
អុក ន. ខ្សែអុក

ឧស ឬ អុស ន. ឧសដុត
អុះ! ឧ. អុះ! វិះធ្លាក់!

អួត កិ. (យំសោក) កុំអួតធ្វើអ្វី
អូដ្ឋ ន. សត្វអូដ្ឋ

អ្នក បុ. ស. មួយនាក់
ណាក់ សព្វ. ពីរនាក់

= ចប់ =

## ផ្សាយចេញពីបណ្ណាគារ ឱុប-ឈឹន ភ្នំពេញ


សរសេរតាមសូត្រខ្មែរ និពន្ធដោយ ជូ ថានី

ពង្សាវតារប្រទេសកម្ពុជា -„- រ.គោវទ

ទុំទាវ (ការសិក្សាស្រាវជ្រាវ) -„- គីម.សែត

កុលាបប៉ៃលិន(ការសិក្សាស្រាវជ្រាវ) -„- -„-

ហង្សយន្ត (ការសិក្សាស្រាវជ្រាវ) -„- -„-

លេខាធិការឯកទេស គីម-សែត ជូ-ថានី

វិធីសម្ពន្ធខ្មែរ យូ-ជិន

សិក្សាអនុពាក្យ និពន្ធដោយ គិត-ហ៊ាន

ឧបករណ៍អនុពាក្យ និពន្ធដោយ គិត-ហ៊ាន


### សៀវភៅបំរុងនឹងចេញ


ការតែងសេចក្ដី (ប្រធានសិក្សាស្រាវជ្រាវ) គីម-សែត

ការតែងសេចក្ដីខ្មែរ(ថ្នាក់បរ. គទ. ទីនមធ្យម.) -„-



រោងពុម្ពវីរិយៈ: តម្លៃ ២០រ០០